## ទីស្ដីការគណៈរដ្ឋមន្ត្រី
## អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស

# សៀវភៅស
# ស្ដីពី
# ការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រ
# នីតិកាលទី៥ នៃរដ្ឋសភា
# នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣

# អារម្ភកថា

កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រជាជនកម្ពុជា ចំនួន ៦៩,៦១% បានទៅបោះឆ្នោត បំពេញកាតព្វកិច្ចក្នុងនាមជាប្រជាពលរដ្ឋ ជ្រើសរើសគណបក្សណាដែលខ្លួនស្រឡាញ់ ទៅតាមឆន្ទៈរៀងៗខ្លួន ដោយសេរី និងសម្ងាត់។ ជាលទ្ធផល គណបក្សប្រជាជនកម្ពុជា ត្រូវបានជ្រើសរើស ដោយទទួលបាន៦៨អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន៥៥អាសនៈ។ ដូច្នេះ ប្រជាពលរដ្ឋកម្ពុជាបានជ្រើសរើសគណបក្សប្រជាជនកម្ពុជា ក្នុងការដឹកនាំប្រទេស សម្រាប់នីតិកាលទី៥ នៃរដ្ឋសភា។ ប៉ុន្តែ គណបក្សសង្គ្រោះជាតិ បានបដិសេធលទ្ធផលនៃការបោះឆ្នោតនេះ ដោយចោទប្រកាន់ថាមានភាពមិនប្រក្រតី និងធ្វើមិនដឹងមិនឮ ចំពោះការពិត ការទទួលស្គាល់របស់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ថាការបោះឆ្នោតនេះ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា។

ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ និងតម្លាភាព គ.ជ.ប បានចងក្រងសៀវភៅស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣។ សៀវភៅសនេះ ឆ្លុះបញ្ចាំងព័ត៌មានទាំងឡាយ ពាក់ព័ន្ធនឹងនីតិវិធីអនុវត្តនៅគ្រប់ដំណាក់កាល ការដោះស្រាយបណ្តឹង និងការចោទប្រកាន់នានា។

សៀវភៅស ដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី បកស្រាយនូវដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ទាំងមូល ដែលបានប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជានិងនីតិវិធីរបស់គ.ជ.ប ព្រមទាំងបង្ហាញនូវល្បិចកលគិតទុកជាមុនរបស់គណបក្សសង្គ្រោះជាតិ ដែលព្យាយាមធ្វើតាមគ្រប់រូបភាពមុនពេលបោះឆ្នោត ក្នុងអំឡុងពេល និងក្រោយពេលបោះឆ្នោត ដើម្បីឈានដល់ការបដិសេធលទ្ធផលនៃការបោះឆ្នោត។

# មាតិកា


**សេចក្តីផ្តើម**

I. **ស្ថានភាពទូទៅនៃការបោះឆ្នោតនៅកម្ពុជា ឆ្នាំ២០១៣**

II. **ល្បិចកលគិតទុកជាមុនដើម្បីបដិសេធលទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ**

១. ការបដិសេធលទ្ធផល នៅមុនការបោះឆ្នោត

២. ឧបាយកលចោទប្រកាន់លើនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត

៣. ការរើសអើងប្រកាន់ពូជសាសន៍ និងបណ្តុះគំនិតញុះញង់ឱ្យមានគំនុំជាតិសាសន៍

៤. ការបំប៉ោងព័ត៌មានមិនពិតដោយ COMFREL ពាក់ព័ន្ធនឹងទឹកខ្មៅ

៥. ការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម

៦. ការប្រកាសបំផ្លើសលទ្ធផលនៃការបោះឆ្នោត

៧. ការព្យាយាមរបស់លោក សម រង្ស៊ី ដើម្បីបដិសេធលទ្ធផលបោះឆ្នោត

៨. ការចោទប្រកាន់ចំពោះគ.ជ.ប

៩. ការចោទប្រកាន់ចំពោះក្រុមប្រឹក្សាធម្មនុញ្ញ

១០. ការទាមទារឱ្យមានការបង្កើតគណៈកម្មការចំរុះ ដោយមានការចូលរួមរបស់សង្គមស៊ីវិល និងអង្គការសហប្រជាជាតិ

III. **អ្នកសង្កេតការណ៍បោះឆ្នោត**

១. តំណាងគណបក្សសង្គ្រោះជាតិ និងអ្នកសង្កេតការណ៍របស់អង្គការ COMFREL

២. អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ

IV. **ដំណោះស្រាយបណ្តឹង**

១. ការដោះស្រាយបណ្តឹងតវ៉ារបស់គ.ជ.ប

២. ការដោះស្រាយបណ្តឹងតវ៉ារបស់ក្រុមប្រឹក្សាធម្មនុញ្ញ

V. **ជំហររបស់សហគមន៍អន្តរជាតិចំពោះការបោះឆ្នោត**

VI. **ការបើកកិច្ចប្រជុំលើកដំបូងរបស់រដ្ឋសភា**

**សន្និដ្ឋាន**

## សេចក្ដីផ្ដើម

ក្រោយពេលរំដោះប្រទេសពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានស្តារ និងកសាងប្រទេសឡើងវិញពីបាតដៃទទេ នៅពេលដែលភាពក្រីក្របានញាំញីលើជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់រូប គ្រប់ច្រកល្ហកនៅទូទាំងប្រទេស។ ដោយសារមានមាគ៌ាដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជា ជាបណ្តើរៗ មាតុភូមិយើង ទទួលបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ ការអភិវឌ្ឍ សេរីភាព ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ។ សមិទ្ធផលជាច្រើនត្រូវបានកសាងឡើងនៅពាសពេញផ្ទៃប្រទេស ហើយការអភិវឌ្ឍកំពុងបន្តដំណើរទៅមុខឥតឈប់ឈរ។ ជោគជ័យដ៏សំខាន់មួយទៀតរបស់ប្រជាពលរដ្ឋកម្ពុជា គឺការផ្តួលរំលំអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហម តាមនយោបាយឈ្នះ-ឈ្នះរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីនៅឆ្នាំ១៩៩៨ ដែលធ្វើឱ្យកម្ពុជាបានស្គាល់នូវសន្តិភាពពេញលេញក្នុងរយៈពេលប្រហែល៥០០ឆ្នាំចុងក្រោយនៃប្រវត្តិសាស្ត្រដ៏យូរលង់របស់ខ្លួន។

ចាប់ពីឆ្នាំ១៩៩៣មក ប្រទេសកម្ពុជាប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញបែបសភានិយម និងអនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស បើកទូលាយឱ្យគ្រប់គណបក្សនយោបាយចូលរួមប្រកួតប្រជែងដោយសេរីនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រព្រឹត្តទៅរៀងរាល់៥ឆ្នាំម្តង។

កន្លងមក ការបង្កើតរាជរដ្ឋាភិបាលជួបបញ្ហារាំងស្ទះ ដោយសារការបង្កើតរដ្ឋាភិបាលទាមទារឱ្យមានសំឡេងគាំទ្រ២/៣ ពីសមាជិករដ្ឋសភាទាំងមូល ហើយគណបក្សនយោបាយមួយចំនួនប្រើសិទ្ធិរបស់ខ្លួន ដើម្បីដាក់លក្ខខណ្ឌទាមទារតួនាទីនិងតំណែងរបស់ពួកគេ ទាំងក្នុងស្ថាប័ននីតិប្រតិបត្តិក៏ដូចជានីតិប្បញ្ញត្តិ។ ដើម្បីចៀសវាងការជាប់គាំងនយោបាយបែបនេះ ទើបរដ្ឋសភាបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅដើមឆ្នាំ២០០៦ ដោយបានប្តូរពីការបោះឆ្នោតទុកចិត្តរាជរដ្ឋាភិបាលពីសំឡេងភាគច្រើន ២/៣ មកជាសំឡេងភាគច្រើនដាច់ខាត (៥០% បូកមួយ) ដោយមានការចូលរួមអនុម័តពីគ្រប់គណបក្សនយោបាយទាំងអស់នៅក្នុងរដ្ឋសភា។ នៅអាណត្តិទី៤ ឆ្នាំ២០០៨-២០១៣ ទោះបីគណបក្សប្រជាជនកម្ពុជាទទួលបាន ៩០អាសនៈក៏ដោយ ក្នុងស្មារតីបង្រួបបង្រួមជាតិ ក៏រាជរដ្ឋាភិបាលចម្រុះត្រូវបានបង្កើតឡើងដដែល ដោយមានការចូលរួមពីគណបក្សហ៊្វុនស៊ិនប៉ិច។

## I. ស្ថានភាពទូទៅនៃការបោះឆ្នោតនៅកម្ពុជា ឆ្នាំ២០១៣

ការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភា បានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ១៥:00 រសៀល នៅការិយាល័យបោះឆ្នោតចំនួន ១៩ ០០៩ នៅទូទាំងប្រទេស។ បើតាមសៀវភៅសស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣ ដែលបានផ្សព្វផ្សាយ

ដោយគ.ជ.ប កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣ បង្ហាញថា ប្រជាជនដែលចេញទៅបោះឆ្នោតមានអត្រា ៦៩,៦១% ស្មើនឹង ៦ ៧៣៥ ២៤៤នាក់ ក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោតចំនួន ៩ ៦៧៥ ៤៥៣នាក់។ បើតាមវិទ្យាស្ថានដើម្បីលទ្ធិប្រជាធិបតេយ្យ និងជំនួយដល់ការបោះឆ្នោត (The Institute for Democracy and Electoral Assistance) អត្រានេះមានកម្រិតខ្ពស់ធៀបជាមួយនឹងប្រទេសមួយចំនួន ដូចជា៖

ប្រទេសហ្វីលីពីន មានអត្រាអ្នកទៅបោះឆ្នោត ៦០,៧% ស្មើនឹងប្រមាណ ៣១លាននាក់ ក្នុងឆ្នាំ២០១៣ ក្នុងចំណោមអ្នកដែលចុះឈ្មោះបោះឆ្នោតជាង ៥២លាននាក់ ឬ៥០,៨% ក្នុងចំណោមអ្នកដែលគ្រប់អាយុបោះឆ្នោតប្រមាណ ៦២លាននាក់។

ប្រទេសឥណ្ឌា មានអត្រាអ្នកទៅបោះឆ្នោត ៥៨,១៩% ស្មើនឹងចំនួនជាង ៤១៧លាននាក់ ក្នុងឆ្នាំ២០០៩ ក្នុងចំណោមអ្នកដែលចុះឈ្មោះបោះឆ្នោតប្រមាណ ៧១៧លាននាក់ ឬ៥៦,៤៨% ក្នុងចំណោមអ្នកដែលគ្រប់អាយុបោះឆ្នោតជាង ៧៣៨លាននាក់។

សហរដ្ឋអាមេរិក មានអត្រាអ្នកទៅបោះឆ្នោត ៤១,៥៩% ស្មើនឹងប្រមាណ ៩០លាននាក់ ក្នុងឆ្នាំ២០១០ ក្នុងចំណោមអ្នកដែលចុះឈ្មោះបោះឆ្នោតប្រមាណ ២១៨លាននាក់ ឬ៣៨,៤៦% ក្នុងចំណោមអ្នកដែលគ្រប់អាយុបោះឆ្នោត ប្រមាណ២៣៥លាននាក់ ។

បរិយាកាសនៃការបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិភាព។ ជោគជ័យនៃការបោះឆ្នោតនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីការវិវត្តជាវិជ្ជមានប្រកបដោយមោទនភាព នូវការអនុវត្តលទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា។ ប្រជាពលរដ្ឋមានសិទ្ធិពេញលេញ ក្នុងការសម្តែងចេញនូវឆន្ទៈរបស់ខ្លួនដោយសេរី នៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោត។ ប្រជាពលរដ្ឋបានចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ដើម្បីសម្តែងចេញនូវការគាំទ្រចំពោះគណបក្សនយោបាយដែលខ្លួនពេញចិត្ត ដោយពុំមានការភ័យខ្លាច។ សកម្មជនគណបក្សនីមួយៗ បានធ្វើសកម្មភាពនយោបាយរបស់ខ្លួនដោយសេរី និងពុំមានការគាបសង្កត់ និងគំរាមកំហែងពីមជ្ឈដ្ឋានណាមួយឡើយ។ ក្នុងដំណើរការបោះឆ្នោតនេះ ពុំមានអំពើហិង្សាធ្ងន់ធ្ងរដែលប៉ះពាល់ដល់ដំណើរការបោះឆ្នោត ហើយក៏ពុំមានឃើញរបាយការណ៍ណាមួយអំពីការរំលោភបំពាន ឬការធ្វើឃាតខាងនយោបាយដល់សមាជិកគណបក្សនយោបាយណាមួយនោះទេ។ ការបោះឆ្នោតបានប្រព្រឹត្តទៅក្រោមការឃ្លាំមើលរបស់អ្នកសង្កេតការណ៍អន្តរជាតិចំនួន២៩២នាក់ និងអ្នកសង្កេតការណ៍ជាតិចំនួន ៤០ ១៤២នាក់ រួមមានអ្នកសង្កេតការណ៍របស់អង្គការ COMFREL ដែលមានវត្តមាននៅគ្រប់ការិយាល័យបោះឆ្នោត ហើយបានសង្កេតឃើញជាទូទៅថា ការបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ តម្លាភាព គ្មានការគំរាមកំហែង គ្មានអំពើហិង្សា និងអាចទទួលយកបាន។

បើទោះបីជាយ៉ាងនេះក្តី គណបក្សប្រឆាំងបានបំពុលបរិយាកាសនៃដំណើរការបោះឆ្នោតនេះជាអាទិ៍ ការឈរជាក្រុមនៅពីមុខការិយាល័យបោះឆ្នោតអុកឡុកនិងរំខានអ្នកបោះឆ្នោតដែលមាន

សម្ព័ន្ធជ្រះដោយរើសអើងថាជាយួន និងបញ្ចុះបញ្ចូលប្រជាពលរដ្ឋឱ្យបោះឆ្នោតឱ្យគណបក្សសង្គ្រោះជាតិ ជាដើម។ គណបក្សប្រឆាំងបានប្រព្រឹត្តនូវទង្វើដែលផ្ទុយនឹងច្បាប់បែបនេះ ដើម្បីជាលេសចោទប្រកាន់ គ.ជ.ប សម្រាប់បម្រើគោលដៅរបស់គេចុងក្រោយនៅពេលដែលគេចាញ់ឆ្នោត។

## II. ល្បិចកលបដិសេធលទ្ធផលបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ

### ១. ការបដិសេធលទ្ធផល នៅមុនការបោះឆ្នោត

ជារៀងរាល់ឆ្នាំ បញ្ជីបោះឆ្នោតត្រូវបានធ្វើបច្ចុប្បន្នភាព ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ (ឬចាប់ពីថ្ងៃទី០១ ខែកញ្ញា នៅក្នុងឆ្នាំមុនការបោះឆ្នោត)។ ចំណែកបញ្ជីបោះឆ្នោតឆ្នាំ២០១៣ ត្រូវបានធ្វើបច្ចុប្បន្នភាពនៅក្នុងឆ្នាំ២០១២ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយទុកពេល ៤ខែ សម្រាប់ការប្តឹងតវ៉ា ឬការប្តឹងជំទាស់នានា ពាក់ព័ន្ធនឹងឈ្មោះរបស់អ្នកបោះឆ្នោត។ ដោយមានចេតនាបង្កើតលេសសម្រាប់ប្រឆាំងតវ៉ានៅក្រោយពេលបោះឆ្នោត គណបក្សប្រឆាំងទាំងពីរ គឺគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានបដិសេធមិនចូលរួមនៅក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នភាពនៃបញ្ជីបោះឆ្នោតនេះ ព្រោះគេដឹងថាបញ្ជីនេះគឺបានមកពីបញ្ជីនៅឆ្នាំ២០១២ ដែលមានលក្ខណៈគ្រប់គ្រាន់អាចទទួលយកបាន។ បន្ទាប់ពីបញ្ជីបច្ចុប្បន្នភាពនេះត្រូវបានប្រកាសផ្សព្វផ្សាយជាសាធារណៈ ហើយក្លាយទៅជាបញ្ជីបោះឆ្នោតផ្លូវការ ក្រុមសម្ព័ន្ធមិត្តនៃគណបក្សប្រឆាំង National Democratic Institute (NDI) បានរៀបចំបញ្ចេញឯកសារ ដោយចោទប្រកាន់ថា គ.ជ.ប បានធ្វើឱ្យបាត់ឈ្មោះរហូតដល់ ១,០៤លាននាក់ ចំណែក COMFREL ក៏បានរៀបចំបញ្ចេញឯកសារមួយផ្សេងទៀត ដោយចោទប្រកាន់ថា គ.ជ.ប បានធ្វើឱ្យបាត់ឈ្មោះអ្នកបោះឆ្នោតរហូតដល់ ១,២៥ លាននាក់ ប៉ុន្តែ COMFREL បាននិយាយថាបញ្ជីបោះឆ្នោតឆ្នាំ២០១២នេះ ល្អប្រសើរជាងបញ្ជីបោះឆ្នោតនៅឆ្នាំ២០០៨ និង២០១១បន្តិច ដែលខ្លួនបានធ្វើការស្ទង់មតិ។

ដោយសំអាងលើទិន្នន័យបានរៀបចំទុកមុនដែលគ្មានមូលដ្ឋានទាំងនេះ និងលេសនៃការមិនចូលរួមរបស់ខ្លួនក្នុងដំណើរការធ្វើបច្ចុប្បន្នភាពនៃបញ្ជីបោះឆ្នោត គណបក្សប្រឆាំងជារឿយៗបានប្រកាសថា ខ្លួននឹងមិនចូលរួមការបោះឆ្នោត ឬបដិសេធលទ្ធផលនៃការបោះឆ្នោត។ ថ្ងៃបោះឆ្នោតមិនទាន់បានមកដល់ផង គណបក្សប្រឆាំងបានបដិសេធលទ្ធផល មុនការបោះឆ្នោតទៅហើយ ប៉ុន្តែខ្លួននៅតែចូលរួមក្នុងការបោះឆ្នោតដដែល។ បញ្ហានៅត្រង់ថា ប្រសិនបើគណបក្សប្រឆាំងឈ្នះឆ្នោត តើខ្លួនបដិសេធលទ្ធផលនៃការបោះឆ្នោតនេះដែរឬទេ។ នេះគឺគ្រាន់តែជាការស្រែកឡូឡាដើម្បីបំភ័ន្តមតិសាធារណៈ ហើយបន្ទាប់ពីការបោះឆ្នោតរួច បង្កើតជាលេសឡាំប៉ាបដិសេធលទ្ធផលនៃការបោះឆ្នោត ប្រសិនបើខ្លួនចាញ់ ប៉ុន្តែសំងំទទួលយកលទ្ធផលប្រសិនបើខ្លួនឈ្នះ។

## ២. ឧបាយកលចោទប្រកាន់លើនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត

ច្បាប់មិនអនុញ្ញាតឱ្យប្តឹងបន្ទាប់ពីផុតរយៈពេលកំណត់នោះទេ។ បើទោះបីដឹងច្បាស់យ៉ាងនេះក៏ដោយ ក៏០៧ខែក្រោយពីបញ្ជីឈ្មោះអ្នកបោះឆ្នោតត្រូវបានបិតផ្សាយជាផ្លូវការ គណបក្សសង្គ្រោះជាតិនៅតែប្តឹងតវ៉ាទៅគ.ជ.បដដែល ដែលបណ្តឹងទាំងនោះភាគច្រើនពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ដែលមិនអាចរកឈ្មោះឃើញនៅក្នុងបញ្ជីបោះឆ្នោត។ ដូច្នេះ ការប្តឹងទាំងនេះគឺគ្រាន់តែជាការបង្កើតអង្គហេតុ ដើម្បីបំភ័ន្តអ្នកដែលពុំបានយល់ដឹងច្បាស់អំពីនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត ឱ្យយល់ឃើញថា គ.ជ.បមានភាពលម្អៀង។ លើសពីនេះ នៅក្នុងដំណាក់កាលនៃការចុះឈ្មោះ និងពិនិត្យឈ្មោះបោះឆ្នោត គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សមិនបានបញ្ជូនតំណាងរបស់ខ្លួនមកចូលរួមឡើយ។ **ទង្វើបែបនេះគឺជាគម្រោងការ ដើម្បីទម្លាក់កំហុសលើគ.ជ.ប ថា បញ្ជីបោះឆ្នោតជាដើមហេតុដែលនាំឱ្យគណបក្សសង្គ្រោះជាតិចាញ់ឆ្នោត។**

កាលពីឆ្នាំ២០០៨ អង្គការ NDI បានចោទថាមានប្រជាពលរដ្ឋ ៨៨នាក់ បានបាត់ឈ្មោះពីបញ្ជីបោះឆ្នោត ហើយបន្ទាប់នោះ គ.ជ.ប រកឃើញថា ១៥នាក់ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០០៧ ១៩នាក់មានឈ្មោះស្ទួននៅក្នុងការិយាល័យបោះឆ្នោតតែមួយ ៧នាក់ចុះឈ្មោះពីរដង និង៩នាក់មានឈ្មោះពីរផ្សេងគ្នា ចំណែក៣១នាក់បានផ្លាស់ទីលំនៅចេញពីឃុំ ២នាក់បាត់បង់សិទ្ធិក្នុងការបោះឆ្នោត ២នាក់ស្លាប់ ២នាក់ពុំមានអាសយដ្ឋាន និង១នាក់ទៀតពុំបានចុះឈ្មោះបោះឆ្នោត។ **តាមការរកឃើញរបស់គ.ជ.ប សបញ្ជាក់ឱ្យឃើញថា ការចោទប្រកាន់របស់ NDI ចំពោះអ្នកបាត់ឈ្មោះទាំង ៨៨នាក់នោះ គឺមិនត្រឹមត្រូវទេ។**

តាមសៀវភៅសរបស់ គ.ជ.ប នៅក្នុងឆ្នាំ២០១៣នេះ អង្គការ NDI បានបដិសេធមិនសហការជាមួយ គ.ជ.ប. ក្នុងការផ្តល់បញ្ជីឈ្មោះអ្នកដែលអះអាងថាបានបាត់ឈ្មោះពីបញ្ជីបោះឆ្នោត ដោយយកលេសថារក្សាការសម្ងាត់។ ចំណែក COMFREL តើមានបានផ្តល់បញ្ជីឈ្មោះអ្នកដែលអះអាងថាបានបាត់ឈ្មោះពីបញ្ជីបោះឆ្នោតទៅឱ្យគ.ជ.ប ដើម្បីផ្ទៀងផ្ទាត់ដែរឬទេ? ប្រសិនបើអង្គការទាំងពីរនេះមានភាពស្មោះត្រង់ និងសុច្ចន្ទៈដើម្បីរកការពិត នោះខ្លួនត្រូវតែសហការជាមួយ គ.ជ.ប ដើម្បីរកឱ្យឃើញការពិត ព្រោះកិច្ចសហការនេះពុំមានច្បាប់ណាហាមឃាត់ឡើយ ហើយធ្វើការកែលម្អបញ្ជីនេះជាបន្តបន្ទាប់ ដូចដែលធ្លាប់បានអនុវត្តពេលកន្លងមក ហើយប្រសិនបើមានការបាត់ឈ្មោះច្រើនមែននោះ តើហេតុអ្វីមិនយកឈ្មោះទាំងនោះមកផ្ទៀងផ្ទាត់ជាមួយ គ.ជ.ប? **ទង្វើខាងលើនេះ បង្ហាញពីពុតត្បុតដែលបានគិតគូរជាមុនរបស់ក្រុមពួកប្រឆាំង។**

## ៣. ការរើសអើងប្រកាន់ពូជសាសន៍ និងបណ្តុះគំនិតញុះញង់ឱ្យមានគំនុំជាតិសាសន៍

ជារឿយៗ គណបក្សសង្គ្រោះជាតិតែងលើកយកបញ្ហាជនជាតិវៀតណាម បញ្ហាព្រំដែនកម្ពុជា-វៀតណាម មកធ្វើជាប្រធានបទវាយប្រហាររាជរដ្ឋាភិបាល ដើម្បីទាក់ទាញទឹកចិត្តអ្នកបោះឆ្នោត ប៉ុន្តែហេតុអ្វីបានជាក្រុមនេះមិនដែលនិយាយដល់បញ្ហាជនជាតិ ឬបញ្ហាព្រំដែនជាមួយថៃ ឬឡាវ?

ជាក់ស្តែង ក្នុងពេលយុទ្ធនាការឃោសនាការស្វែងរកសំឡេងឆ្នោត ក៏ដូចជាមុនយុទ្ធនាការ ក្រុមគណបក្សប្រឆាំងបានប្រើពាក្យសំដីអសុរោះ មាក់ងាយប្រជាជនកម្ពុជាដែលជាអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា និងអ្នកដឹកនាំ ដោយជេរ និងលាបពណ៌ថា «ក្បាលយួន ខ្លួនខ្មែរ» «ពួកអាយ៉ងយួន» «ពួកអានាំយួនចូលស្រុក» «ពួកអាលក់ដីឱ្យយួន» ឬ«ពួកអាយួន» ជាដើម។ ទង្វើទាំងនេះ សបញ្ជាក់ឱ្យឃើញច្បាស់ ពីសកម្មភាពបំបែកបំបាក់សាមគ្គីផ្ទៃក្នុង ការបង្រួបបង្រួមជាតិ ដែលអាចជាប្រភពនៃអំពើហិង្សា និងអាចបង្កជាជម្លោះជាមួយប្រទេសជិតខាង។ ដូច្នេះ សំណួរសួរថា តើប្រជាពលរដ្ឋដែលទៅបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជានោះ គឺជាយួនមែនដែរឬទេ។ លើសពីនេះទៅទៀត តើការដែលគណបក្សសង្គ្រោះជាតិបណ្តុះគំនិតមនុស្សឱ្យចេះប្រើប្រាស់សំដីអសុរោះបែបនេះ គឺជាមធ្យោបាយត្រឹមត្រូវឬ ដើម្បីការពារសិទ្ធិមនុស្ស ឬពង្រឹងលទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដនៅកម្ពុជា ?

ប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសកម្ពុជាបានបង្ហាញឱ្យឃើញថា ការរើសអើងពូជសាសន៍ នៅក្នុងសម័យលន់ នល់ និងក្នុងសម័យខ្មែរក្រហម បានធ្វើឱ្យប្រទេសកម្ពុជាធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាម និងមហាវិនាសកម្ម។ ជាពិសេស របបខ្មែរក្រហម ដែលបានសម្លាប់ប្រជាពលរដ្ឋកម្ពុជាអស់ជាង ៣លាននាក់ ដែលក្នុងនោះមួយចំនួនត្រូវបានចោទថា ជាយួន។ តើនៅពេលនោះ មានប្រទេសណាខ្លះដែលបានចេញមុខ ឬអើពើចំពោះសោកនាដកម្មរបស់ប្រជាជនកម្ពុជាកន្លងមកដែរឬទេ ?

ពាក់ព័ន្ធទៅនឹងឥរិយាបថរបស់គណបក្សប្រឆាំង ការរើសអើងប្រកាន់ពូជសាសន៍ និងការបណ្តុះគំនិតញុះញង់ឱ្យមានគំនុំជាតិសាសន៍ ត្រូវបានចាត់ទុកថាជាការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិជាចំបងរបស់ប្រជាពលរដ្ឋ។ តើអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក ស៊ូរយ៉ា ស៊ូប៊ែឌី និងមជ្ឈដ្ឋានមួយចំនួន ធ្លាប់មានប្រតិកម្មដែរឬទេ ?

ប្រសិនបើឆ្លើយថា មិនដែលធ្លាប់មានប្រតិកម្មទេ នោះមានន័យថា លោក ស៊ូរយ៉ា ស៊ូប៊ែឌី និងមជ្ឈដ្ឋានមួយចំនួន ដែលធ្លាប់តែស្រែកថា ខ្លួនជាអ្នកការពារសិទ្ធិមនុស្សនោះ ប្រាកដជាអនុវត្តស្តង់ដាពីរហើយ ចំពោះការគោរពសិទ្ធិមនុស្សនៅកម្ពុជា។

គណបក្សសង្គ្រោះជាតិ ត្រូវដឹងថា រដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ *«ការប្រើសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ គឺមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អ្នកដទៃទេ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់»*។

### ៤. ការបំប៉ោងព័ត៌មានមិនពិត ដែលថាទឹកខ្មៅអាចលុបលាងជ្រះរបស់ COMFREL

នៅមុនថ្ងៃបោះឆ្នោតមួយថ្ងៃ ដែលជាថ្ងៃស្ងប់ស្ងាត់ COMFREL បានបញ្ចេញព័ត៌មានបំផ្លើសដោយអះអាងថា ទឹកខ្មៅដែលប្រើសម្រាប់ជ្រលក់ម្រាមដៃសម្គាល់អ្នកដែលបានបោះឆ្នោតរួច ជាទឹកខ្មៅដែលអាចលាងសម្អាតចេញយ៉ាងងាយស្រួល ក្នុងរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ។ នេះជាលើកទី

មួយហើយដែលបញ្ហាទឹកខ្មៅនេះ ត្រូវបានលើកឡើងនៅក្នុងការបោះឆ្នោតនៅកម្ពុជា។ ការអះអាងនេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងបានធ្វើឱ្យមហាជនយល់ច្រឡំថា អ្នកបោះឆ្នោតអាចមានលទ្ធភាពបោះឆ្នោតបានច្រើនដង។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីការបោះឆ្នោតពុំមានពាក្យប្ដឹងណាមួយពាក់ព័ន្ធនឹងករណីនេះទេ។

ទោះបីជាពុំមានពាក្យបណ្ដឹងពាក់ព័ន្ធនឹងទឹកខ្មៅក៏ដោយ ប៉ុន្តែនៅទីស្នាក់ការគណបក្សសង្គ្រោះជាតិទួលគោក លោក កឹម សុខា បាននិយាយថា «យើងរកឃើញនៅថ្ងៃបោះឆ្នោត ទឹកខ្មៅអាចលាងជ្រះដោយវត្ថុងាយរកនៅតាមទីផ្សារ នៅកន្លែងអ៊ុតសក់ ឬក៏ប្រើទឹកសាប៊ូលាយខ្លាញ់បន្តិចក៏អាចលាងជ្រះដែរ។ ដូច្នេះ គោលការណ៍មួយជានាថា មនុស្សបានបោះឆ្នោតមួយសន្លឹក គឺមិនអាចធានាបានដោយសារទឹកខ្មៅអាចលាងជ្រះ»។ ពាក់ព័ន្ធនឹងករណីនេះ លោក កឹម សុខា មិនដែលបានបង្ហាញច្បាស់ថាមានមនុស្សប៉ុន្មាននាក់ដែលបន្ទាប់ពីបោះឆ្នោតហើយ លាងសម្អាតទឹកខ្មៅជ្រះ រួចទៅបោះឆ្នោតម្ដងទៀតបាននោះទេ។ នៅទីលានប្រជាធិបតេយ្យ កាលពីថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៣ នៅពេលដែលលោក កឹម សុខា លើកដៃសំពះ ឃើញមានស្នាមទឹកខ្មៅនៅជាប់ដៃយ៉ាងច្បាស់ក្រឡែតនៅឡើយ។

យោងតាមលោក Devin Morrow ដែលជាអ្នកសង្កេតការណ៍របស់អង្គការ COMFREL បាននិយាយថា «ទោះបីជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍របស់អង្គការ COMFREL នៅភាគពាយ័ព្យនៃប្រទេសកម្ពុជាបាននិយាយថា ការធ្វើតេស្តទៅលើទឹកខ្មៅបង្ហាញថា វាពិតជាមិនអាចលុបលាងជ្រះឡើយ។ នៅខេត្តរតនៈគីរី ក្រចេះ និងមណ្ឌលគីរី ការប៉ុនប៉ងលុបលាងទឹកខ្មៅដោយប្រើប្រាស់សារធាតុផ្សេងៗ មិនបានទទួលជោគជ័យដែរ»។

អ្នកសង្កេតការណ៍មួយក្រុមមានចំនួន១៤នាក់ មកពីវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ បានធ្វើការសង្កេតនៅការិយាល័យបោះឆ្នោតចំនួន២០ ដោយបានបញ្ជាក់ថា៖ «ក្រុមអ្នកសង្កេតការណ៍របស់យើងបានអញ្ជើញអ្នកបោះឆ្នោត មកធ្វើការសាកល្បងលាងជម្រះទឹកខ្មៅ បន្ទាប់ពីពួកគេបានដើរចេញពីការិយាល័យបោះឆ្នោត បានប៉ុន្មានជំហាន ឬប៉ុន្មាននាទីប៉ុណ្ណោះ»។ កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ បានបង្ហាញតាមរយៈរូបថត និងវីដេអូអំពីការលាងជម្រះទឹកខ្មៅថា ទឹក ទឹកសាប៊ូ ក្រូចឆ្មារ អាល់កុល និងសាំង មិនអាចលុបលាងជ្រះទាំងស្រុងបានទេ។ ម្យ៉ាងទៀត អ្នកសង្កេតការណ៍អន្តរជាតិមួយចំនួន ដែលបានសាកល្បងជ្រលក់ទឹកខ្មៅ ក៏បានទទួលស្គាល់ថា ទឹកខ្មៅនោះមិនអាចលុបលាងជ្រះបានដែរ។ ការពិត ទឹកខ្មៅដែលត្រូវបានផលិតឡើងដោយក្រុមហ៊ុនរដ្ឋរបស់ឥណ្ឌា គឺមានគុណភាពខ្ពស់ ដែលធ្លាប់បានប្រើប្រាស់នៅកម្ពុជាតាំងពីឆ្នាំ១៩៩៨ និងជាអំណោយរបស់រដ្ឋាភិបាលឥណ្ឌា ហើយក៏ត្រូវបានប្រើប្រាស់សម្រាប់ការបោះឆ្នោតនៅក្នុងបណ្ដាប្រទេសមួយចំនួន ដូចជា ប្រទេសឥណ្ឌា អាហ្វហ្គានីស្ថាន ម៉ាឡេស៊ី នីហ្សេរីយ៉ា សិង្ហបូរី អាហ្វ្រិកខាងត្បូង និងថៃ។

## ៥. ការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម

សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភា ឆ្នាំ២០១៣ គ.ជ.ប បានផ្តល់មធ្យោបាយផ្សេងៗ ទៅគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីទាំងអស់ ដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីកម្មវិធីនយោបាយរបស់គណបក្សនីមួយៗ ដោយធានាតម្លាភាព និងសមភាពចំពោះការប្រើប្រាស់វិទ្យុ និងទូរទស្សន៍រដ្ឋ។ ទន្ទឹមនឹងនេះ គ.ជ.ប ក៏បានណែនាំដល់វិទ្យុរដ្ឋ និងទូរទស្សន៍ជាតិកម្ពុជាឱ្យរក្សាពេល ៤ម៉ោង ក្នុងមួយថ្ងៃ នៅក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ដែលគណបក្សនីមួយៗមានពេល ៣០នាទីក្នុងមួយថ្ងៃ នៅតាមស្ថានីយនីមួយៗ ដើម្បីផ្សព្វផ្សាយគោលនយោបាយគណបក្សរបស់ខ្លួន។

ក្រៅពីនេះ ចំពោះបណ្តាញវិទ្យុនិងទូរទស្សន៍ឯកជន ព្រមទាំងសារព័ត៌មានក្នុងស្រុក ការផ្សាយសារនយោបាយរបស់គណបក្សណាមួយ គឺយោងទៅតាមការព្រមព្រៀងគ្នាជាលក្ខណៈឯកជន និងអត្ថប្រយោជន៍ធុរកិច្ចរវាងគណបក្ស និងម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ។ គណបក្សនយោបាយនីមួយៗបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានទៅតាមលទ្ធភាពរៀងៗខ្លួន។

ដោយឡែក ក្រៅពីបានទទួលម៉ោងផ្សាយតាមវិទ្យុនិងទូរទស្សន៍រដ្ឋ គណបក្សសង្គ្រោះជាតិថែមទាំងបានជួលម៉ោង តាមរយៈវិទ្យុឯកជនក្នុងស្រុកបន្ថែមទៀតជាច្រើន ដែលក្នុងនោះរួមមាន វិទ្យុសំបុកឃ្មុំ FM ១០៥ វិទ្យុមហានគរ FM ៩៣.៥ និងវិទ្យុសំឡេងស្ត្រី FM ១០២ និងវិទ្យុសំឡេងប្រជាធិបតេយ្យ VOD ជាដើម ហើយវិទ្យុទាំងអស់នេះបានជួលម៉ោងទៅឱ្យវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) និងវិទ្យុអាស៊ីសេរី (RFA) ដើម្បីផ្សព្វផ្សាយព័ត៌មានបរទេសជាខេមរភាសា បន្ថែមពីលើម៉ោងដែលវិទ្យុ VOA និងRFA បានផ្សាយបន្តផ្ទាល់ចេញពីទីក្រុងវ៉ាស៊ីនតោន។ វិទ្យុទាំងពីរនេះ ដែលទទួលថវិកាពីប្រទេសណាមួយនោះ និងដែលផ្សាយព័ត៌មានដោយលម្អៀង និងរំលោភវិជ្ជាជីវៈសារព័ត៌មាន គឺជាឧបករណ៍នយោបាយបម្រើឱ្យគណបក្សប្រឆាំងយ៉ាងផ្ចាប់មុខ។ VOA និង RFA នៅតែបន្តផ្សព្វផ្សាយសកម្មភាពចុះឃោសនានៅតាមមូលដ្ឋាន កម្មវិធីនយោបាយ និងសកម្មភាពពាក់ព័ន្ធដទៃទៀត ដែលភាគច្រើនសុទ្ធសឹងជាព័ត៌មានប្រឌិត បំផ្លើស និងមួលបង្កាច់ការពិត តាំងពីមុន និងក្រោយការបោះឆ្នោត។ កាសែតភ្នំពេញប៉ុស្តិ៍ និងខេមបូឌាដេលី ក៏បានធ្វើដូចគ្នាយ៉ាងដូច្នេះដែរ។

រាជរដ្ឋាភិបាលបានកត់សម្គាល់ឃើញថា មេដឹកនាំគណបក្សង្គ្រោះជាតិបានប្រើប្រាស់សិទ្ធិសេរីភាពពេញលេញក្នុងការធ្វើសន្និសីទសារព័ត៌មានជាបន្តបន្ទាប់ ចាប់តាំងពីថ្ងៃបោះឆ្នោត និងការប្រកាសលទ្ធផលផ្លូវការបណ្តោះអាសន្ន។

បណ្តាញផ្សព្វផ្សាយសង្គម រួមមាន Facebook, Youtube និង Twitter បានផ្សព្វផ្សាយរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងនយោបាយ និងរូបភាពផ្សេងៗ ដែលមានចរិតជាការបំផ្លើស ការប្រឌិត ការញុះញង់ ឬជាពាក្យចចាមអារ៉ាម ដែលគណបក្សសង្គ្រោះជាតិ និងអ្នកគាំទ្រខ្លួន បានបង្កើតឡើងក្នុងគោលបំណងបំពុលបរិយាកាសសង្គម កេងចំណេញនយោបាយ ឬញុះញង់ប៉ុនប៉ងបំបែកបំបាក់ផ្ទៃ

ក្នុងគណបក្សប្រជាជនកម្ពុជា ដោយមិនបានគិតគូរដល់សុចរិតភាពនៃព័ត៌មាននោះទេ។ ក៏ប៉ុន្តែ បើទោះបីជាមាន ការផ្សព្វផ្សាយហួសព្រំដែននៃសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលមិនទាន់បានចាត់វិធានការតាមផ្លូវច្បាប់ ឬធ្វើការហាមឃាត់ ក្នុងរូបភាពណាមួយនៅឡើយ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលនៅតែជានាឱ្យមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។

ដូច្នេះ ការផ្សព្វផ្សាយព័ត៌មានរបស់គណបក្សនីមួយៗ តាមគ្រប់រូបភាពនៃប្រព័ន្ធផ្សព្វផ្សាយផ្សេងៗនៅក្នុងការបោះឆ្នោតឆ្នាំ២០១៣ គឺមានតុល្យភាព។ ប្រជាពលរដ្ឋខ្មែរដែលជាម្ចាស់ឆ្នោត ក៏បានទទួលព័ត៌មានគ្រប់ៗគ្នា ពីគ្រប់គណបក្សនយោបាយ។

## ៦. ការប្រកាសបំផ្លើសលទ្ធផលនៃការបោះឆ្នោត

បន្ទាប់ពីការរាប់សន្លឹកឆ្នោត នៅគ្រប់ការិយាល័យបោះឆ្នោតនៅទូទាំងប្រទេសរួចមក នាល្ងាចថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដោយផ្អែកលើតួលេខក្នុងទម្រង់បែបបទ ១១០៤ នៅតាមការិយាល័យបោះឆ្នោតនីមួយៗដែលបានបញ្ជូនមក គ.ជ.ប ដោយគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងដោយគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតរួចមក គ.ជ.ប បានផ្សព្វផ្សាយលទ្ធផលបឋមតាមទូរទស្សន៍ជាតិកម្ពុជា ហើយលទ្ធផលនោះបង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងចំនួន ៣ ២៣៥ ៩៦៩ សំឡេង ចំណែកគណបក្សសង្គ្រោះជាតិទទួលបានសំឡេងចំនួន ២ ៩៤៦ ១៧៦ សំឡេង។

ក្រៅពីការគណនាលទ្ធផលរបស់ គ.ជ.ប គណបក្សនយោបាយនីមួយៗ ឬ អង្គការនានាក៏អាចសរុបលទ្ធផលបឋមដោយខ្លួនឯងបានដែរ តាមរយៈតួលេខក្នុងទម្រង់១១០៤ ដែលទទួលបានពីតំណាងរបស់ខ្លួន ឬអ្នកសង្កេតការណ៍នៅតាមការិយាល័យបោះឆ្នោត ឬតាមតួលេខក្នុងទម្រង់១១០២ ដែលត្រូវបានបិទផ្សាយនៅមុខការិយាល័យបោះឆ្នោតទាំងអស់។

ជាក់ស្តែង គណបក្សប្រជាជនកម្ពុជាបានសរុបលទ្ធផលបោះឆ្នោតបឋមរបស់ខ្លួន តាមរយៈតួលេខដែលទទួលបានពីតំណាងនៅតាមការិយាល័យបោះឆ្នោត នៅទូទាំងប្រទេស ដែលមានតួលេខក្នុងទម្រង់១១០៤ ឬតួលេខក្នុងទម្រង់១១០២ ហើយការបូកសរុបនេះបានបង្ហាញឱ្យឃើញថា គណបក្សប្រជាជនកម្ពុជាទទួលបាន ៦៨អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន ៥៥ អាសនៈ។

នៅល្ងាចថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ គណបក្សសង្គ្រោះជាតិបានប្រកាសថា ខ្លួនឈ្នះឆ្នោត ដោយពុំដឹងថាគណបក្សនេះយកតួលេខចេញពីប្រភពណាមកបូកសរុបនោះទេ ប៉ុន្តែភ្លាមៗនោះ លោក សម រង្ស៊ី ក៏បានប្រកាសដកពាក្យនោះវិញ។

ផ្ទុយពីការប្រកាសរបស់គណបក្សសង្គ្រោះជាតិ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៣ COMFREL បានប្រកាសថា ខ្លួនបានគណនាឃើញថា គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេង ៤៩,៤៩% នៃសំឡេងឆ្នោតសរុប ហើយគណបក្សសង្គ្រោះជាតិទទួលបានសំឡេង ៤៣,០៥% ដែលធ្វើឱ្យគណបក្ស

ប្រជាជនកម្ពុជាទទួលបាន ៦៧អាសនៈ និងគណបក្សសង្គ្រោះជាតិទទួលបាន៥៦អាសនៈ។ ចាប់តាំងពីពេលប្រកាសនោះមក ជាការចម្លែក COMFREL លែងបន្តផ្សព្វផ្សាយតួលេខនេះទៀត ដើម្បីការពារការប្រឌិតលទ្ធផលនៃការបោះឆ្នោតរបស់សម្ព័ន្ធមិត្តខ្លួន។

ជាបន្តទៀត នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៣ នៅស្រុកកងមាស ខេត្តកំពង់ចាម កឹម សុខា បានប្រកាសថា *«នៅម៉ោង៥ រាប់ទៅឃើញគណបក្សសង្គ្រោះជាតិ ឡើងដល់ ៧៦កៅអី។ គេ (មិនដឹងនរណាទេ) រាយការណ៍ប្រាប់អង្គទូតថា យើងឈ្នះហើយ ស្រាប់តែឈប់រាប់តែម្តង។ គេ (គណបក្សប្រជាជនកម្ពុជា) ប្រកាសថា គេឈ្នះវិញ គឺគេមានល្បិចលួចយើងហើយ។ ... អង្គការអន្តរជាតិ ទូតនៅប្រទេសប្រជាធិបតេយ្យ និងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ គេដឹងច្បាស់ថា គណបក្សសង្គ្រោះជាតិ ជាអ្នកឈ្នះហើយ»*។ នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៣ នៅទីលានប្រជាធិបតេយ្យ លោក កឹម សុខា បាននិយាយប្រាប់សកម្មជនរបស់ខ្លួនថា *«ខ្ញុំអត់ប្រាប់ថាបានពីបរទេសណាទេ ខ្ញុំជាមួយ ឯកឧត្តម សម រង្ស៊ី នៅថ្ងៃបោះឆ្នោត ម៉ោង ៥-៦ ល្ងាច ទទួលបានព័ត៌មានច្បាស់ណាស់ គេប្រាប់ថាយើងបាន៧៦កៅអី ស្រាប់តែមួយម៉ោងក្រោយមក ក្រឡាប់ចាក់ទៅអ៊ីចេះវិញ»* ។

ការពោលអះអាងខាងលើ គ្រាន់តែជាការប្រឌិត ដើម្បីភូតកុហកប្រជាពលរដ្ឋ និងសាធារណមតិអន្តរជាតិតែប៉ុណ្ណោះ ហើយអ្នកដែលរាយការណ៍ទៅអង្គទូតនោះ គឺគ្មាននរណាក្រៅពីលោក កឹម សុខា ខ្លួនឯងនោះទេ ឬក៏ជាការប្រឌិតរឿងទាំងស្រុង។

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ នៅទីស្នាក់ការគណបក្ស ក្រុងភ្នំពេញ លោក កឹម សុខា បានប្រកាសទៀតថា គណបក្សខ្លួនបានទទួលយ៉ាងតិច ៦៣អាសនៈ ប៉ុន្តែនៅថ្ងៃផ្សេងទៀត (នៅថ្ងៃទី៤ ថ្ងៃទី៦ និងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៣) លោក កឹម សុខា បែរជាប្រកាសថា គណបក្សសង្គ្រោះជាតិទទួលបាន ៧៦ អាសនៈទៅវិញ ដោយផ្អែកលើការបូកសរុបលទ្ធផលរបស់អង្គការក្រៅរដ្ឋាភិបាលមួយ។ សំណួរសួរថា៖

- តើអង្គការនោះជាអង្គការណាមួយ?
- តើអង្គការអន្តរជាតិ ទូតនៅប្រទេសប្រជាធិបតេយ្យ និងអង្គការក្រៅរដ្ឋាភិបាលណាខ្លះដែលដឹងថាគណបក្សសង្គ្រោះជាតិឈ្នះ ហើយបានប្រភពមកពីណា?
- តើតួលេខនៅក្នុងទម្រង់១១០៤ ដែលតំណាងរបស់គណបក្សសង្គ្រោះជាតិទទួលបាន នៅគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ ឬតួលេខនៅក្នុងទម្រង់១១០២ ដែលបិទនៅមុខការិយាល័យបោះឆ្នោតនៅឯណា ហើយតើបានយកតួលេខទាំងនោះមកបូកសរុបដែរឬទេ ឬមួយបានតួលេខមកពីប្រភពណា ដើម្បីបូកឱ្យឃើញថាគណបក្សសង្គ្រោះជាតិទទួលបានម្តង ៧៦អាសនៈ ម្តង៦៣អាសនៈ?

- បើគណបក្សសង្គ្រោះជាតិចោទថាតួលេខផ្លូវការរបស់គ.ជ.ប ជាតួលេខក្លែងក្លាយ ចុះតួលេខដែលគ្មានប្រភពច្បាស់លាស់របស់ខ្លួនវិញ បែរជាត្រឹមត្រូវវិញឬយ៉ាងណា?
- គណបក្សសង្គ្រោះជាតិបានចោទថាទម្រង់១១០៤ ជាទម្រង់ក្លែងក្លាយ ឬកោសលុប តើទម្រង់១១០៤ដែលក្លែងក្លាយ ឬកោសលុបនោះ មាននៅការិយាល័យបោះឆ្នោតណាខ្លះ ដែលខុសពីទម្រង់១១០៤ដែលតំណាងរបស់ខ្លួនមាន?

**ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការអះអាងនេះ ផ្អែកទៅលើតួលេខក្នុងទម្រង់បែបបទដើម១១០៤ ដែលតំណាងគណបក្សប្រជាជនកម្ពុជា និងតំណាងគណបក្សសង្គ្រោះជាតិ ក៏ដូចជាអ្នកសង្កេតការណ៍ របស់អង្គការ COMFREL ទទួលបានពីប្រធានការិយាល័យបោះឆ្នោតនីមួយៗ ឬតួលេខក្នុងទម្រង់១១០២ ដែលបិទនៅមុខការិយាល័យបោះឆ្នោតនីមួយៗនោះ ការបូកសរុបលទ្ធផលបឋមនៃការបោះឆ្នោត នឹងមិនមានភាពខុសគ្នានោះទេ ហើយក៏ដូចគ្នានឹងលទ្ធផលបឋម ដែល គ.ជ.បបានប្រកាសដែរ។**

នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៣ លោក សម រង្ស៊ី បានលើកឡើងថា *«គណបក្សប្រជាជនកម្ពុជាបានអះអាងថា ខ្លួនមានសមាជិកពី ៦ ទៅ ៧លាននាក់ ដល់បោះឆ្នោតបានតែ ៣លាននាក់ មិនដឹងថាទៅណាអស់។ គេថាបាន ៣លាននាក់ គឺគាត់ច្រើនបានមកពីសំឡេងសម្លុត សំឡេងលួច សំឡេងបន្លំ សំឡេងទិញ សំឡេងឈ្មោះខ្មោច សំឡេងយួន សំឡេងខ្យល់»។* គ្មាននរណាម្នាក់ជឿសម្តីរបស់ សម រង្ស៊ី ទេ ហើយប្រសិនបើពិតដូចសំដីបែបនេះមែន នោះគណបក្សប្រជាជនកម្ពុជា ស្ទើរតែគ្មានអ្នកគាំទ្រ។ តើនេះគឺជាការពិតដែរឬទេ ហើយនរណាខ្លះដែលជឿសំដីបែបនេះរបស់ សម រង្ស៊ី?

បន្ថែមលើនេះទៀត សម រង្ស៊ី បានញុះញង់ឱ្យប្រជាពលរដ្ឋនៅតាមខេត្តនៅជិតៗទីក្រុងភ្នំពេញ *«ចូលរួមមហាបាតុកម្មមួយដ៏ធំក្នុងប្រវត្តិសាស្ត្រ... ឱ្យញ័រផែនដី... ដើម្បីរំដោះប្រទេសជាតិយើង... ឱ្យទាល់តែបាន បើយើងបណ្តោយឱ្យពួកផ្តាច់ការ ពួកដែលសម្លាប់ជាតិឯង ពួកពុករលួយដល់ឆ្អឹង ពួកឱ្យយួនខ្ញីដែលសម្លាប់ជាតិឯង បើយើងបណ្តោយឱ្យតែ បួន ប្រាំឆ្នាំទៀត ជាតិយើងរលាយហើយ ដូច្នេះយើងអត់សុខចិត្តទេ ត្រៀមខ្លួនទាំងអស់គ្នា សង្គ្រោះជាតិយើងឱ្យទាល់តែបាន។»*

គណបក្សសង្គ្រោះជាតិត្រូវតែដឹងឱ្យច្បាស់ថា ប្រសិនបើអស់លោក ភូតភរកុហក ប្រជាពលរដ្ឋនៅពេលនេះ មិនយូរមិនឆាប់ក្នុងពេលអនាគត ពួកគាត់នឹងដឹងថាក្រុមអស់លោក ជាមេកុហកដ៏ពូកែផុតលេខ។ ទោះបីជា នៅចំពោះព្រះភ័ក្ត្រព្រះអង្គចេក ព្រះអង្គចម ឬនៅចំពោះមុខលោកតាដំបងក្រញូង ដែលប្រជាពលរដ្ឋគោរពកោតខ្លាចបារមីដ៏ស័ក្តិសិទ្ធិ ក៏មេគណបក្សប្រឆាំងទាំងពីរនេះ ហ៊ានបំផ្លើសការពិត និយាយកុហក ដោយពុំខ្លាចក្រែងបារមីស័ក្តិសិទ្ធិ តាមបរាមុខនោះឡើយ។ តើជីវិតនយោបាយរបស់មេដឹកនាំទាំងពីរនេះ នឹងត្រូវបញ្ចប់ ដោយសារអំពើភូតភរកុហកមិនចេះចប់បែបនេះឬយ៉ាងណា?

## ៧. ការព្យាយាមរបស់លោក សម រង្ស៊ី ដើម្បីបដិសេធលទ្ធផលបោះឆ្នោត

មួយថ្ងៃមុនថ្ងៃបោះឆ្នោត ក្នុងសវនាការជាមួយអ្នកសង្កេតការណ៍អន្តរជាតិនៅស្នាក់ការបក្សរបស់ខ្លួន លោក សម រង្ស៊ី និងលោក កឹម សុខា បានប្រកាសថា មិនទទួលស្គាល់ គ.ជ.ប ហើយនឹងបដិសេធលទ្ធផលនៃការបោះឆ្នោត ហើយលោក សម រង្ស៊ី បានបញ្ជាក់ថា គណបក្សសង្គ្រោះជាតិអាចនឹងឈ្នះ។ នៅក្នុងសវនាការនោះ ឥស្សរៈជនជាន់ខ្ពស់ជាអ្នកសង្កេតការណ៍អន្តរជាតិមួយរូបបានសួរ លោក សម រង្ស៊ី ថា **«បើមិនទទួលស្គាល់ គ.ជ.ប និងមិនទទួលស្គាល់លទ្ធផលបោះឆ្នោត តើគណបក្សរបស់លោកចូលរួមបោះឆ្នោតធ្វើអី?» «ហើយចុះបើគណបក្សរបស់លោកឈ្នះវិញ តើលោកនៅតែបដិសេធលទ្ធផលបោះឆ្នោតដែរឬទេ?»** ចំពោះសំណួរទាំងនេះ លោក សម រង្ស៊ី និងលោក កឹម សុខា បែរជាមិនឆ្លើយតប ហើយបង្វែរការពិភាក្សាទៅលើប្រធានបទផ្សេងវិញ។ ឥរិយាបថបែបនេះនាំឱ្យគេយល់ថា គណបក្សសង្គ្រោះជាតិនឹងទទួលយកលទ្ធផលបោះឆ្នោតប្រសិនបើខ្លួនឈ្នះ ហើយនឹងបដិសេធប្រសិនបើខ្លួនចាញ់ ដែលនេះមិនមែនជាឥរិយាបថរបស់កីឡាករ ឬបង្ហាញពីគោលជំហររបស់អ្នកដែលមានលទ្ធភាពធ្វើជាមេដឹកនាំនោះទេ។

កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៣ នៅក្នុងខេត្តកំពង់ស្ពឺ លោក សម រង្ស៊ី បាននិយាយថា៖ «......ជនរួមជាតិទាំងអស់ នេះជាឱកាសចុងក្រោយហើយ ប្រសិនបើយើង មិនសង្គ្រោះជាតិទេ បួន ឬប្រាំឆ្នាំទៀតគឺយឺតពេលទៅហើយ ដោយសារជនជាតិវៀតណាមនឹងរស់នៅពេញប្រទេសកម្ពុជា ហើយយើងនឹងក្លាយជាទាសករនៃប្រទេសវៀតណាម....»។ សម្តីនេះមានន័យថា ចំពោះ លោក សម រង្ស៊ី នឹងគ្មានការបោះឆ្នោតទេនៅពេលខាងមុខ ដោយសារតែនៅពេលនោះ ប្រទេសកម្ពុជានឹងក្លាយជាផ្នែកមួយនៃប្រទេសវៀតណាម និងជា «ទាសកររបស់វៀតណាម» ទៅហើយ។

ជាងនេះទៀត នៅលើទំព័រ Facebook របស់លោក សម រង្ស៊ី នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣ លោកសម រង្ស៊ី បានសរសេរថា៖ «ខ្ញុំដឹងថាសកម្មភាពបែបនេះ (ការចល័តកម្លាំងប្រដាប់អាវុធ) កើតឡើងតាមការបញ្ជារបស់បុគ្គលកាន់អំណាចម្នាក់ប៉ុណ្ណោះ ហើយខ្ញុំក៏ដឹងទៀតថា បងប្អូន កូនក្មួយពលទាហាន ប៉ូលីស និងកងកម្លាំងប្រដាប់អាវុធទាំងអស់ កំពុងទន្ទឹងរង់ចាំរដ្ឋាភិបាលថ្មី ដែលនឹងផ្តល់ប្រាក់ខែជូនយ៉ាងតិច១លានរៀលក្នុងមួយខែ ហើយរស់នៅក្រោមដំបូលរដ្ឋាភិបាលថ្មី ប្រកបដោយការយកចិត្តទុកដាក់ទទួលខុសត្រូវ និងមានតម្លៃក្នុងសង្គម។ ដូច្នេះនៅពេលនេះ ជាឱកាសមាសរបស់បងប្អូនក្នុងការរួមគ្នាក្រោកឡើង ជាមួយប្រជាពលរដ្ឋយើង និងជាមួយយុវជនសង្គ្រោះជាតិរបស់យើង ដើម្បីទាមទារឱ្យមានការផ្លាស់ប្តូរ ឆ្ពោះទៅរកការបង្កើតរដ្ឋាភិបាលថ្មីក្នុងឆ្នាំ២០១៣នេះឱ្យទាល់តែបាន»។ នេះមិនមែនជាការអំពាវនាវ ដើម្បីឱ្យពលទាហានទាំងអស់ទៅបោះឆ្នោតឱ្យគណបក្សសង្គ្រោះជាតិទេ ពីព្រោះការបោះឆ្នោតបានបញ្ចប់ហើយ។ វាជាការអំពាវនាវឱ្យពួកគេក្រោកឈរឡើងបះបោរ ហើយបង្កើតរដ្ឋាភិបាលថ្មីមួយ ហើយពួកគេត្រូវបានសន្យាថានឹងទទួលបានរង្វាន់ជាការដំឡើងប្រាក់ខែ ប្រសិនបើពួកគេធ្វើដូច្នេះ។ លើសពីនេះទៀត លោក សម រង្ស៊ី បានលើកទឹកចិត្តកងកម្លាំងប្រដាប់អាវុធ និង

ប៉ូលីសឱ្យរត់ចោលតួនាទីរបស់ខ្លួន ដើម្បីចូលរួមនៅក្នុងបាតុកម្មតវ៉ារបស់គណបក្សសង្គ្រោះជាតិ។ ល្បិចកលជាច្រើនដ៏ទៃ ទៀតរបស់លោកសម រង្ស៊ី និងលោកកឹម សុខា មានជាអាទិ៍ ៖

- ធ្វើការបំផ្លើសលទ្ធផលនៃការបោះឆ្នោត នៅគ្រប់វេទិកាសាធារណៈ ដែលជាការបង្ហាញដល់ប្រជាពលរដ្ឋថា គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោត គឺដោយសារតែលួចបន្លំសន្លឹកឆ្នោត ហើយក្រុមរបស់ខ្លួនគឺជាអ្នករកយុត្តិធម៌ឱ្យម្ចាស់ឆ្នោត ប៉ុន្តែតាមពិតក្រុមនេះ កំពុងតែយកឆន្ទៈរបស់ម្ចាស់ឆ្នោតធ្វើអាជីវកម្ម ដើម្បីផលប្រយោជន៍នយោបាយរបស់ខ្លួន។

- ញុះញង់អ្នកបោះឆ្នោតឱ្យមានកំហឹងឈឺចាប់ ហើយចូលរួមបាតុកម្មដែលពួកគេហៅថា មហាបាតុកម្មសម្តែងឆន្ទៈរបស់ប្រជាពលរដ្ឋ។ ទង្វើនេះគឺជាវិធីចុងក្រោយតែមួយគត់ ក្នុងការកៀរគរ និងប្រើប្រាស់កម្លាំងមហាជនដើម្បីតវ៉ាលទ្ធផលនៃការបោះឆ្នោត សំដៅសម្រេចឱ្យបាននូវមហិច្ឆិតារបស់ខ្លួនក្នុងគោលបំណងដណ្តើមអំណាចឱ្យខាងតែបាន ដែលទង្វើនេះគឺផ្ទុយពីគោលការណ៍គ្រឹះនៃប្រជាធិបតេយ្យ និងប្រាសចាកពីគោលការណ៍ច្បាប់ជាធរមាន។

- ធ្វើការចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងប្រើពាក្យសំដីអសុរោះដោយគ្មានការទទួលខុសត្រូវ គឺជាលេសដើម្បីបណ្តុះផ្នត់គំនិតអវិជ្ជមានចំពោះគណបក្សប្រជាជនកម្ពុជា និងថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ដើម្បីឱ្យពួកគេអាចមានឱកាសបន្តអាជីពនយោបាយ និងដើម្បីទាក់ទាញសមានចិត្តរបស់អ្នកគាំទ្រក្នុងរយៈពេល៥ឆ្នាំទៅមុខទៀត។

ការធ្វើបែបនេះ ដោយសារតែក្រុមគណបក្សប្រឆាំងសង្ឃឹមថា ខ្លួននឹងទទួលបានការគាំទ្របន្ថែមទៀត ទាំងផ្នែកនយោបាយ និងហិរញ្ញវត្ថុពីគ្រប់មជ្ឈដ្ឋានអ្នកគាំទ្ររបស់ខ្លួន ជាពិសេសពីមជ្ឈដ្ឋានមួយចំនួន ដែលមានជំហរអមិត្ត និងគំនិតទុទិដ្ឋិនិយមចំពោះរាជរដ្ឋាភិបាលកម្ពុជា។

ដូច្នេះ ការព្យាយាមតាមគ្រប់រូបភាពរបស់លោក សម រង្ស៊ី និងលោក កឹម សុខា មិនបានទទួលជោគជ័យនោះទេ ផ្ទុយទៅវិញ នឹងធ្វើឱ្យមេបក្សទាំងពីរកាន់តែអស់សង្ឃឹមខ្លាំងឡើងៗ។ លោក សម រង្ស៊ី យល់ថា ឆ្នាំ ២០១៣ នេះគឺជាឱកាសចុងក្រោយតែមួយគត់ ដើម្បីសម្រេចក្តីស្រមើស្រមៃរបស់ខ្លួនក្លាយជានាយករដ្ឋមន្ត្រី។ ប៉ុន្តែ បើបរាជ័យយ៉ាងដូច្នេះ កម្លាំងជំរុញដែលបានកើតឡើងដោយការរួបរួមគ្នានៃគណបក្សប្រឆាំងទាំងពីរ នឹងមិននៅឋិតថេរក្នុងរយៈពេលប្រាំឆ្នាំតទៅទៀតនោះទេ។ គណបក្សថ្មីនេះអាចនឹងត្រូវបែកបាក់គ្នាទៅវិញ នៅពេលដែលពួកគេបានបរាជ័យនៅក្នុងសមរភូមិរួម ហើយនៅពេលដែលការខ្វែងគំនិតគ្នាកាន់តែរីកធំឡើងៗ ជាពិសេសពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ទាំងទិដ្ឋភាពនយោបាយ និងសេដ្ឋកិច្ច នៅពេលខាងមុខ ។

## ៨. ការចោទប្រកាន់ចំពោះគ.ជ.ប

គ.ជ.ប ដែលជាស្ថាប័នឯករាជ្យគ្រប់គ្រងការបោះឆ្នោត ត្រូវបានបង្កើតឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(ច.ប.ត.រ)។ គ.ជ.ប មានកាតព្វកិច្ចអនុវត្តតាម ច.ប.ត.រ ដែលតម្រូវឱ្យសមាជិកត្រូវតែមានភាពអព្យាក្រឹត និងមិនលម្អៀង។ លើសពីនេះទៀត សមាជិក គ.ជ.ប

ត្រូវលាលែងពីគណបក្សនយោបាយ ដែលពាក់ព័ន្ធមុនចូលកាន់តំណែង។ ស្រដៀងគ្នានេះដែរ សមាជិកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ពុំត្រូវបានជ្រើសតាំងដោយឈរលើមូលដ្ឋានពាក់ព័ន្ធនឹងគណបក្សនយោបាយទៀតទេ។

គ.ជ.ប ធ្លាប់បានរៀបចំការបោះឆ្នោតចំនួន ១១លើក រួចមកហើយ រួមមានការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដោយទទួលបានការកោតសរសើរពីសំណាក់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងបណ្តាប្រទេសជាមិត្ត។

តាមរយៈសៀវភៅសរបស់ គ.ជ.ប ដែលបានចេញផ្សាយនាពេលថ្មីៗនេះសបញ្ជាក់ឱ្យឃើញថា នៅក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត គ.ជ.ប បានធ្វើតាមនីតិវិធីត្រឹមត្រូវតាមច្បាប់កំណត់ ដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋទាំងអស់អាចទៅចុះឈ្មោះ អាចទៅកែឈ្មោះខុស ឬក៏កែតម្រូវថ្ងៃខែឆ្នាំកំណើត និងភេទជាដើម។ មិនតែប៉ុណ្ណោះ សម្រាប់បញ្ជីបោះឆ្នោតឆ្នាំ២០១៣នេះ គ.ជ.ប បានធ្វើការពន្យាពេលទៅដល់៤ខែ ដែលជាធម្មតាមានតែមួយខែទេ សម្រាប់ការចុះឈ្មោះ ការផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោត។

គ.ជ.ប ក៏បានបង្កលក្ខណៈ និងបង្កើតបរិយាកាសឱ្យដំណើរការនៃយុទ្ធនាការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា។ គ្រប់គណបក្សនយោបាយទាំងអស់មានសិទ្ធិពេញលេញក្នុងការធ្វើយុទ្ធនាការ ទោះជាទ្រង់ទ្រាយតូច ឬ ធំក៏ដោយ។

កន្លងមក គណបក្សប្រឆាំងបានទាមទារឱ្យគ.ជ.ប រាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យមួយចំនួន ប៉ុន្តែការទាមទាររបស់ខ្លួនមិនបានបង្ហាញភស្តុតាងច្បាស់លាស់ឡើយ។ ការទាមទារនេះមិនអាចធ្វើទៅបានទេ ដោយសារៈ(១) នៅតាមការិយាល័យបោះឆ្នោតនីមួយៗ គ្មានការប្តឹងតវ៉ាអំពីការលួចបន្លំសន្លឹកឆ្នោត (២) បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច រាល់ទម្រង់បែបបទដែលកត់ត្រាលទ្ធផលបោះឆ្នោតត្រូវបានចុះហត្ថលេខា ដោយគ្មានការជំទាស់ ពីតំណាងអ្នកសង្កេតការណ៍ នៅតាមការិយាល័យបោះឆ្នោតនីមួយៗនោះឡើយ (៣) ក្នុង ច.ប.ត.រ មិនអនុញ្ញាតឱ្យគ.ជ.បរាប់សន្លឹកឆ្នោតឡើងវិញនៅការិយាល័យណាទេ នៅពេលដែលគ្មានភស្តុតាងច្បាស់លាស់ និងគ្មានការប្តឹងតវ៉ាពីតំណាងគណបក្សដែលមានវត្តមាននៅការិយាល័យនោះ (៤) មិនមានការសម្រេចណាមួយពីក្រុមប្រឹក្សាធម្មនុញ្ញដើម្បីឱ្យគ.ជ.ប ធ្វើការរាប់សន្លឹកឆ្នោតឡើងវិញនោះទេ។

គណបក្សប្រឆាំងគ្រាន់តែស្រែកទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ ដែលគ្រាន់តែជាលេសសម្រាប់ពង្រឹងការភូតកុហករបស់ខ្លួនឱ្យកាន់តែមានទម្ងន់ថែមទៀត ថា គ.ជ.បលួចបន្លំសន្លឹកឆ្នោត។

នៅគ្រប់ដំណាក់កាលនៃដំណើរការ នៅតាមការិយាល័យបោះឆ្នោតនីមួយៗ តំណាងមកពីគណបក្សទាំងអស់ដែលចូលរួមការបោះឆ្នោត មានវត្តមាន និងបានចុះហត្ថលេខាលើឯកសារពាក់ព័ន្ធដើម្បីបញ្ជាក់ថានីតិវិធីត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ហើយការរាប់សន្លឹកឆ្នោត និងតួលេខនៃសំឡេងឆ្នោតដែលត្រូវបានកត់ត្រាពិតជាត្រឹមត្រូវ ដូចដែលតំណាងគណបក្សនីមួយៗទទួលបាននៅក្នុងទម្រង់១១០៤ ដែលប្រធានការិយាល័យផ្តល់ជូន។ អ្នកសង្កេតការណ៍មានវត្តមានធ្វើជាសាក្សីនៅក្នុងដំណើរការបោះឆ្នោតតាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់ និងទទួលបានទម្រង់១១០៤ដែរ។ តំណាងគណបក្សនៅតាមគ្រប់ការិយាល័យទាំង១៩០០៩ ពុំបានបដិសេធមិនព្រមចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនៃការបោះឆ្នោតនោះទេ។ នេះគឺជាភស្តុតាងយ៉ាងច្បាស់បញ្ជាក់ថា ដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតគឺមានភាពរលូន និងប្រកបដោយតម្លាភាព ដែលផ្ទុយទាំងស្រុងទៅនឹងអ្វីដែលគណបក្សប្រឆាំងបានប្រឹងស្រែកបំផ្លើសការពិត។

ដូច្នេះ តាមការរៀបរាប់ខាងលើនេះ គ.ជ.ប បានអនុវត្តការងារទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងនីតិវិធីដែលបានកំណត់យ៉ាងត្រឹមត្រូវ និងមិនលម្អៀងដូចការចោទប្រកាន់របស់គណបក្សសង្គ្រោះជាតិដែលថា គ.ជ.បមិនឯករាជ្យ និងជាឧបករណ៍របស់គណបក្សប្រជាជនឡើយ។ តាមរយៈនីតិវិធីដ៏មានតម្លាភាព និងប្រទាក់ក្រឡាគ្នានេះ គ្មាននរណាម្នាក់ អាចលួចបន្លំសន្លឹកឆ្នោតដូចការចោទប្រកាន់របស់គណបក្សប្រឆាំងនោះទេ។

## ៩. ការចោទប្រកាន់ចំពោះក្រុមប្រឹក្សាធម្មនុញ្ញ

បន្ទាប់ពីក្រុមប្រឹក្សាធម្មនុញ្ញចេញសេចក្តីសម្រេចលើរាល់បណ្តឹងតវ៉ារួចមក គណបក្សប្រឆាំងបានបដិសេធនូវសេចក្តីសម្រេចរបស់ស្ថាប័នកំពូលនេះ ហើយបានចោទប្រកាន់ថាសេចក្តីសម្រេចនេះមិនយុត្តិធម៌ និងមានទំនោរលំអៀងទៅរកគណបក្សប្រជាជនកម្ពុជា។

យោងតាមរដ្ឋធម្មនុញ្ញ និង ច.ប.ត.រ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានា ការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់។ ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិសម្រេចលើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក៩រូបដែលទទួលអាណត្តិ៩ឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ១ភាគ៣ ត្រូវផ្លាស់ថ្មីក្នុងរយៈពេល ៣ឆ្នាំម្តងៗ។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រធានមានសំឡេងឧត្តមានុភាពក្នុងករណីបែកសំឡេងជាពីរស្មើគ្នា។ មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងមុខតំណែង ការកាន់

តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬ អនុប្រធានសហជីព។

តាមរយៈសមាសភាពនេះ យើងសង្កេតឃើញថា សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវបាន តែងតាំងចេញពីស្ថាប័នកំពូលបីផ្សេងគ្នា ដូច្នេះ មិនមានបុគ្គល ស្ថាប័ន ឬគណបក្សនយោបាយណាមួយ មានឥទ្ធិពល ដោយផ្ទាល់ ឬដោយប្រយោល ទៅលើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនោះទេ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអនុភាពអនុវត្ត ទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

## ១០.ការទាមទារឱ្យមានការបង្កើតគណៈកម្មការចំរុះ ដោយមានការចូលរួមរបស់សង្គមស៊ីវិល និង អង្គការសហប្រជាជាតិ

ក្រោយពីការបោះឆ្នោតមួយថ្ងៃ គណបក្សសង្គ្រោះជាតិបានចោទប្រកាន់ ថាមានភាពមិន ប្រក្រតីជាច្រើនក្នុងដំណើរការបោះឆ្នោតនេះ ហើយក៏បានស្នើសុំបង្កើតយន្តការថ្មីមួយគឺ «គណៈកម្មការ ចម្រុះ» ឬ «គណៈកម្មការពិសេស» ដែលមិនស្ថិតក្នុងក្របខ័ណ្ឌ ច.ប.ត.រ ដើម្បីស៊ើបអង្កេតនូវអ្វីដែល ពួកគេហៅថាជាភាពមិនប្រក្រតី ដោយស្នើសុំឱ្យគណៈកម្មការនេះ ស្ថិតក្រោមការដឹកនាំរបស់អង្គការ សហប្រជាជាតិ ឬអង្គការមិនមែនរដ្ឋាភិបាលណាមួយ ដោយទុក គ.ជ.ប ឱ្យមានតួនាទីត្រឹមតែជាអ្នក សម្របសម្រួលប៉ុណ្ណោះ។ យន្តការនេះបានធ្វើឱ្យគ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចអនុវត្តមុខងារ និងកាតព្វកិច្ចរបស់ខ្លួនដែលបានចែងក្នុង ច.ប.ត.រ និងរដ្ឋធម្មនុញ្ញ។ កន្លងមក គ.ជ.ប បានបំពេញ តួនាទីដ៏ឧត្តុង្គឧត្តមរបស់ខ្លួនបានល្អប្រសើរ ហើយបានរៀបចំការបោះឆ្នោតសកល ការបោះឆ្នោត ព្រឹទ្ធសភា និងការបោះឆ្នោតឃុំ-សង្កាត់ បានចំនួន ១១ដងរួចមកហើយ។

សំណើនៃការសុំបង្កើតយន្តការថ្មីរបស់គណបក្សសង្គ្រោះជាតិ គឺជាសំណើដែលមិនអាចទទួល យក និងអនុវត្តបាន ដោយឈរលើមូលហេតុមួយចំនួន ដូចខាងក្រោម៖

- កម្ពុជាជារដ្ឋអធិបតេយ្យ នីតិរដ្ឋ ដែលមានច្បាប់ មានយន្តការយុត្តាធិការច្បាស់លាស់សម្រាប់ រៀបចំដំណើរការបោះឆ្នោត និងដោះស្រាយវិវាទក្នុងដំណើរការបោះឆ្នោត។
- ការស្នើឱ្យបង្កើតយន្តការថ្មី គឺជាការបំពានលើរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ និង ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានចែងថា គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ គឺ ជាយន្តការសម្រាប់ដំណើរការ និងដោះស្រាយរាល់វិវាទទាក់ទងនឹងដំណើរការនៃការបោះឆ្នោត។
- គ.ជ.ប បានប្រកាសលទ្ធផល បណ្ដោះអាសន្ននៃការបោះឆ្នោត នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១៣ ហើយរាល់ពាក្យបណ្ដឹងអំពីភាពមិនប្រក្រតី ត្រូវបានដោះស្រាយចប់សព្វគ្រប់ ប្រកបដោយ តម្លាភាព និងយុត្តិធម៌ ដោយ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ។ លទ្ធផលផ្លូវការនៃការបោះឆ្នោតត្រូវ បានប្រកាសនាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៣ រួចហើយ។

- ក្នុងព្រះរាជសាររបស់ព្រះមហាក្សត្រ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣ ក៏បានបញ្ជាក់យ៉ាងច្បាស់ថា ការដោះស្រាយបញ្ហានានារបស់ជាតិគួរផ្អែកលើរដ្ឋធម្មនុញ្ញ និងប្រគល់តួនាទីទៅស្ថាប័នមានសមត្ថកិច្ច ដែលកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នានារបស់ជាតិយើង។

គ.ជ.បបានអំពាវនាវឱ្យគ្រប់គណបក្សនយោបាយ អង្គការសហប្រជាជាតិ អង្គការសង្គមស៊ីវិលចូលរួមជាអ្នកសង្កេតការណ៍ ក្នុងដំណើរការស៊ើបអង្កេតនូវរាល់ភាពមិនប្រក្រតីដែលគណបក្សប្រឆាំងបានប្ដឹងតវ៉ា ដោយ គ.ជ.ប ដឹកនាំដំណើរការស៊ើបអង្កេតនេះ។

ក្នុងស្មារតីបង្រួបបង្រួមជាតិ និងដំហរទន់ភ្លន់ គណបក្សប្រជាជនកម្ពុជាបានបញ្ជូនតំណាងរបស់ខ្លួនចូលរួមជាអ្នកសង្កេតការណ៍ក្នុងដំណើរការស៊ើបអង្កេតនេះ។ ផ្ទុយទៅវិញ គណបក្សសង្គ្រោះជាតិនៅតែប្រើប្រាស់ឧបាយកល ដោយទទូចទាមទារឱ្យអង្គការសហប្រជាជាតិ ឬអង្គការក្រៅរដ្ឋាភិបាលដឹកនាំដំណើរការស៊ើបអង្កេតនេះ ដោយគេដឹងថា សំណើនេះមិនអាចទទួលយកបានទេ ពីព្រោះផ្ទុយនឹងច្បាប់ និងរដ្ឋធម្មនុញ្ញ។

ការទាមទាររបស់គណបក្សសង្គ្រោះជាតិ គឺជាសំណើដែលរំលោភច្បាប់ និងគោលការណ៍នីតិរដ្ឋ ធ្វើឱ្យបាត់បង់អធិបតេយ្យភាព និងឯករាជ្យភាព ហើយជាទង្វើបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់ស្ថាប័នធម្មនុញ្ញរបស់រដ្ឋ និងច្បាប់ជាតិជាធរមាន។ ដូច្នេះគ្មានអ្វីចាំបាច់ក្នុងការបង្កើតយន្តការថ្មីនេះទេ។

## III. អ្នកសង្កេតការណ៍បោះឆ្នោត

### ១. តំណាងគណបក្សសង្គ្រោះជាតិ និងអ្នកសង្កេតការណ៍របស់អង្គការ COMFREL

នៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត គណបក្សសង្គ្រោះជាតិតែងតែមានតំណាងរបស់ខ្លួននៅជាប់ជានិច្ច ជាមួយអ្នកសង្កេតការណ៍របស់គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស និងអង្គការ COMFREL ដែលបានធ្វើជាសាក្សីនៃការបោះឆ្នោត តាំងពីការត្រួតពិនិត្យហិបឆ្នោតការបោះឆ្នោត ការបើកនិងបិទហិបឆ្នោត ការរាប់សន្លឹកឆ្នោត និងការដឹកជញ្ជូនហិបឆ្នោតទៅកាន់ទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និង គ.ជ.ប។ តំណាងគណបក្សនយោបាយដែលបានចូលរួមទាំងនោះ សុទ្ធតែបានចុះហត្ថលេខាលើទម្រង់ពាក់ព័ន្ធទាំងអស់ ដែលជាលទ្ធផលនៃការបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតនីមួយៗ ផ្ទុយទៅវិញ ប្រសិនបើមានភាពមិនប្រក្រតីណាមួយនោះ អ្នកសង្កេតការណ៍ទាំងនេះច្បាស់ជាបដិសេធមិនព្រមចុះហត្ថលេខា ឬប្ដឹងតវ៉ាភ្លាមៗនៅការិយាល័យបោះឆ្នោតតែម្ដង។ ទោះជាមានវត្តមានរបស់តំណាងគណបក្សសង្គ្រោះជាតិនៅគ្រប់ការិយាល័យបោះឆ្នោតក៏ដោយ ហើយតំណាងទាំងនោះបានចុះហត្ថលេខាលើរាល់ទម្រង់ ១១០២ ១១០៨ និងផ្ទាំងក្រដាសធំ ដែលបញ្ជាក់ពីលទ្ធផលដែលទទួលបានពីការិយាល័យបោះឆ្នោតនីមួយៗក៏ដោយ ក៏គណបក្សនេះនៅតែបដិសេធលទ្ធផលបោះឆ្នោតដដែល ដោយចោទប្រកាន់យ៉ាង

ងងើលថា ការបោះឆ្នោតនេះពោរពេញដោយភាពមិនប្រក្រតី។ ប្រសិនបើដូចការចោទប្រកាន់នេះមែន មានន័យថាតំណាងគណបក្សសង្គ្រោះជាតិក៏បានចូលរួមក្នុងការលួចបន្លំសន្លឹកឆ្នោតនេះដែរ។

ទង្វើនេះគ្មានអ្វីដែលថ្មីនោះទេ ពីព្រោះនៅរៀងរាល់ការបោះឆ្នោត គណបក្សដែលដឹកនាំដោយ លោក សម រង្ស៊ី តែងតែបដិសេធជានិច្ចនូវលទ្ធផលនៃការបោះឆ្នោត។ ចំណែក COMFREL វិញ ដែល តាំងខ្លួនថា ជាយន្តការសង្កេតការណ៍ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នោះ ហេតុអ្វីបានជា មានជំហរលម្អៀងទៅតាមគណបក្សប្រឆាំង ថាការបោះឆ្នោតនេះមានភាពមិនប្រក្រតី នៅពេលដែល តំណាងរបស់ខ្លួនបានចូលរួមក្នុងគ្រប់ដំណើរការនៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

## ២. អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ

សម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ គ.ជ.ប បានទទួលស្គាល់អ្នកសង្កេតការណ៍បោះឆ្នោតមកពី ប្រទេសនានា គណបក្សនយោបាយ ស្ថានឯកអគ្គរដ្ឋទូត រាជទូត អង្គការ និងសមាគម ចំនួន៣៥ ដែលមានអ្នកសង្កេតការណ៍អន្តរជាតិសរុបចំនួន ២៩២នាក់។ អ្នកសង្កេតការណ៍ជាតិមានសរុបចំនួន ៤០ ១៤២នាក់ ដែលក្នុងនោះមានអ្នកសង្កេតការណ៍របស់អង្គការ COMFREL នៅគ្រប់ការិយាល័យ បោះឆ្នោត។ ផ្អែកលើសេចក្តីសម្រេចរបស់ គ.ជ.ប ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ប៉ុន្មានថ្ងៃមុនថ្ងៃ បោះឆ្នោតប៉ុណ្ណោះ គ.ជ.ប ក៏បានទទួលស្គាល់អ្នកសង្កេតការណ៍ចំនួន ៩ ៩៣១នាក់ មកពីគណបក្ស សម រង្ស៊ី និងអ្នកសង្កេតការណ៍ចំនួន ៤៧៨០នាក់ មកពីគណបក្សសិទ្ធិមនុស្ស។ បើពិនិត្យចំនួន តំណាងរបស់គណបក្សប្រជាជនកម្ពុជា គឺស្មើនឹងចំនួនតំណាងរបស់គណបក្សសង្គ្រោះជាតិ ប៉ុន្តែនៅ ក្នុងការិយាល័យបោះឆ្នោតនីមួយៗនៅមានអ្នកសង្កេតការណ៍របស់អង្គការ COMFREL និងអ្នកសង្កេត ការណ៍របស់គណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សថែមទៀត ដូច្នេះ មានន័យថា ក្នុងមួយ ការិយាល័យបោះឆ្នោតមានអ្នកសង្កេតការណ៍ ២នាក់ មកពីគណបក្សប្រជាជនកម្ពុជា ទល់នឹង ៥នាក់ មកពីក្រុមប្រឆាំង។

ចំពោះអ្នកសង្កេតការណ៍អន្តរជាតិ មានជាអាទិ៍ ឥស្សរជនជាន់ខ្ពស់មកពីប្រទេស និងអង្គការ មួយចំនួន ដូចជា អតីតប្រធានរដ្ឋសភាប្រាំអាណត្តិនៃប្រទេសហ្វីលីពីន អតីតអនុប្រធានាធិបតី ឥណ្ឌូនេស៊ី អតីតឧបនាយករដ្ឋមន្ត្រីកាណាដា អតីតឧបនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋកូរ៉េ សមាជិក ព្រឹទ្ធសភានៃប្រទេសប៉ាគីស្ថាន ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតនៃប្រទេសហ្វីលីពីន ប្រទេសថៃ និងប្រទេសមីយ៉ាន់ម៉ា សមាជិកគណៈកម្មការរៀបចំការបោះឆ្នោត ម៉ាឡេស៊ី ឡាវ រុស្ស៊ី និងប្រធាន លេខាធិការដ្ឋានអាស៊ានទទួលបន្ទុកអភិវឌ្ឍកិច្ចការសហគមន៍។ អ្នកសង្កេតការណ៍ទាំងនោះបានចេញ សេចក្តីថ្លែងការណ៍របស់ខ្លួន ចាត់ទុកថាការបោះឆ្នោតនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅកម្ពុជា ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ប្រកបដោយសន្តិភាពនិងគ្មានអំពើហិង្សា។

សេចក្តីថ្លែងការណ៍របស់សន្និសីទអន្តរជាតិនៃគណបក្សនយោបាយនៅអាស៊ី (ICAPP) និងរបស់ចលនាអ្នកប្រជាធិបតេយ្យនិយមកណ្តាលអន្តរជាតិអាស៊ីប៉ាស៊ីហ្វិក (CAPDI) ដែលដឹកនាំដោយឯកឧត្តមអតីតប្រធានរដ្ឋសភាហ្វីលីពីន និងឯកឧត្តមអតីតអនុប្រធានាធិបតីឥណ្ឌូនេស៊ី បានលើកឡើងថា «ស្ថាប័ន ICAPP និង CAPDI ចាត់ទុកការបោះឆ្នោតនៅកម្ពុជាថាជាជ័យជំនះនៃឆន្ទៈរបស់ប្រជាពលរដ្ឋ និងជាជ័យជំនះរបស់ប្រជាជនកម្ពុជា ក្នុងការស្វែងរកនូវការកសាងអនាគតរបស់ពួកគេឱ្យកាន់តែល្អប្រសើរឡើង។ ការបោះឆ្នោតនេះ គឺសេរី យុត្តិធម៌ និងមានតម្លាភាព ហើយជាពិសេសបានប្រព្រឹត្តទៅដោយសន្តិភាព គ្មានអំពើហឹង្សា និងដោយរលូន ដែលជាសក្ខីភាពចំពោះការពិតថាប្រជាធិបតេយ្យកម្ពុជា មិនត្រឹមតែមានភាពចាស់ទុំប៉ុណ្ណោះទេ ថែមទាំងនយោបាយក៏មានភាពចាស់ទុំផងដែរ។ យើងសូមសម្តែងនូវការអបអរសាទរអស់ពីដួងចិត្តជូនចំពោះប្រជាជន គណបក្សនយោបាយទាំងឡាយ មេដឹកនាំ សារព័ត៌មាន សង្គមស៊ីវិល និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរបស់កម្ពុជា ចំពោះជោគជ័យ និងការប្រព្រឹត្តទៅដោយមានសណ្តាប់ធ្នាប់នៃការបោះឆ្នោតនេះ»។

ប្រធានប្រតិភូនៃគណៈកម្មការរៀបចំការបោះឆ្នោតរបស់ប្រទេសមួយចំនួនទៀត ក៏បានវាយតម្លៃខ្ពស់ផងដែរ ចំពោះបទពិសោធន៍ដែលទទួលបានពីការបោះឆ្នោតនៅកម្ពុជា ហើយបានសម្តែងនូវការពេញចិត្តចំពោះបរិយាកាសនៅមុនថ្ងៃបោះឆ្នោត ថ្ងៃបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ដែលប្រកបទៅដោយភាពរលូន និងសន្តិភាព ព្រមទាំងអះអាងថា ការបោះឆ្នោតនេះជាការបោះឆ្នោតប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

## IV. ដំណោះស្រាយបណ្តឹង

### ១. ការដោះស្រាយបណ្តឹងតវ៉ារបស់គ.ជ.ប

នៅម៉ោង៩ព្រឹកនាថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ គ.ជ.ប បានប្រកាសលទ្ធផលបណ្តោះអាសន្ន តាមទូរទស្សន៍ជាតិកម្ពុជា បន្ទាប់ពីបានដោះស្រាយពាក្យប្តឹងចំនួន១៣ និងចេញសេចក្តីសម្រេចលើបណ្តឹងចំនួន៤ ដោយអនុលោមតាម ច.ប.ត.រ និងបទបញ្ជានិងនីតិវិធី ដោយបានចោទសួរដើមបណ្តឹងផ្ទាល់ ព្រមទាំងពិនិត្យភស្តុតាងដែលផ្តល់ដោយដើមបណ្តឹងរួចមក។

### ២. ការដោះស្រាយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះបណ្តឹងតវ៉ា

គណបក្សសង្គ្រោះជាតិបានដាក់ពាក្យបណ្តឹងចំនួន១៥ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ជំទាស់នឹងសេចក្តីសម្រេចរបស់គ.ជ.ប។ ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយពាក្យប្តឹងបានចប់សព្វគ្រប់ ដោយបានបញ្ជាឱ្យគ.ជ.ប បើកកញ្ចប់សុវត្ថិភាព «ក» នៅក្នុងខេត្តចំនួន៤ គឺ ខេត្តក្រចេះ បាត់ដំបង សៀមរាប និងកណ្តាល។

គ.ជ.ប បានបើកកញ្ចប់សុវត្ថិភាព «ក» ទៅតាមដីកាបង្គាប់របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយមានវត្តមានតំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងគ.ជ.ប តំណាងគណបក្សប្រជាជនកម្ពុជា តំណាងគណបក្សសង្គ្រោះជាតិ តំណាងគណបក្សហ៊្វុនស៊ិនប៉ិច អ្នកសារព័ត៌មាន រួមទាំងអ្នកសង្កេតការណ៍មកពីអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ហើយលទ្ធផលបង្ហាញថា៖

- នៅខេត្តក្រចេះ ក្នុងចំណោមការិយាល័យបោះឆ្នោតចំនួន១៣ ដែលបានពិនិត្យនោះ កញ្ចប់សុវត្ថិភាព «ក» ចំនួន៨ មិនបានបិទ ប៉ុន្តែបន្ទាប់ពីបានពិនិត្យរាល់ទម្រង់ផ្សេងៗនៅពេលរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផល គ.ជ.ប បានរកឃើញថា តួលេខចំនួនសន្លឹកឆ្នោតដែលគណបក្សនីមួយៗទទួលបាន ពុំមានការប្រែប្រួលឡើយ នៅការិយាល័យបោះឆ្នោតនីមួយៗ។

- នៅខេត្តសៀមរាប ក្នុងចំណោមការិយាល័យបោះឆ្នោតចំនួន១២ កញ្ចប់សុវត្ថិភាព «ក» ចំនួន៧ មិនត្រូវបានបិទ រីឯទម្រង់បែបបទលេខ១១០២ មិនត្រូវបានកត់ត្រាជាកំណត់ហេតុ នៅការិយាល័យ១ ប៉ុន្តែមានហត្ថលេខារបស់មន្ត្រីការិយាល័យបោះឆ្នោត និងភ្នាក់គណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ ។ ប៉ុន្តែ ទម្រង់បែបបទលេខ១១០៨[1] ១១០៤ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត មានទិន្នន័យដូចគ្នានៅការិយាល័យបោះឆ្នោតនេះ។

ទោះបីជាកញ្ចប់សុវត្ថិភាព «ក» ដែលបានរៀបរាប់ខាងលើ ពុំបានបិទត្រឹមត្រូវ ដោយសារការធ្វេសប្រហែសរបស់មន្ត្រីការិយាល័យក៏ដោយ ប៉ុន្តែកញ្ចប់សុវត្ថិភាព «ក» នេះត្រូវបានដាក់ក្នុងកញ្ចប់ «ខ» បិទជិតនៅការិយាល័យបោះឆ្នោតរួចហើយ មន្ត្រីការិយាល័យបោះឆ្នោតទាំងអស់ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ បានបញ្ជូនកញ្ចប់ «ខ» បិទជិតនេះ ទៅកាន់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដោយមានហត្ថលេខាប្រគល់-ទទួលជាសំអាង។

ថ្ងៃបន្ទាប់មក ដោយកំណត់ពេលវេលាច្បាស់លាស់ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតបានបើកកញ្ចប់ «ខ» នៅចំពោះមុខតំណាងគណបក្ស និងអ្នកសង្កេតការណ៍។ បន្ទាប់ពីបានបំពេញរបាយការណ៍បូកសរុបទូទាំងឃុំសង្កាត់រួចមក កញ្ចប់ «ខ» ដែលមានកញ្ចប់សុវត្ថិភាព «ក» នៅខាងក្នុងនោះត្រូវបានដាក់ចូលក្នុងកញ្ចប់ «គ» រួចបិទជិត។ កញ្ចប់ «គ» ត្រូវបានបញ្ជូនទៅកាន់គណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត ជាមួយកញ្ចប់ «គ ពិសេស» មួយទៀត អមដំណើរដោយមន្ត្រីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត តំណាងគណបក្ស និងអ្នកសង្កេតការណ៍។

កញ្ចប់ «គ» និងកញ្ចប់ «គ ពិសេស» ត្រូវបានប្រគល់ជូនគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត ដោយមានចុះហត្ថលេខាប្រគល់-ទទួលពីគណៈកម្មការ ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងតំណាងគណបក្ស។ គណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត បើកកញ្ចប់ «គ ពិសេស» នៅចំពោះមុខតំណាងគណបក្ស និងអ្នកសង្កេតការណ៍។ បន្ទាប់ពីបានបំពេញរបាយការណ៍បូកសរុបទូទាំងរាជធានីខេត្តរួចមក កញ្ចប់ «ឃ» ត្រូវបានបិទជិត រួចបញ្ជូនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

[1] តារាងកត់ត្រាសំឡេងឆ្នោត។

អមដំណើរដោយមន្ត្រីគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត តំណាងគណបក្ស និងអ្នកសង្កេតការណ៍។

ដំណើរការបញ្ជូនកញ្ចប់«ឃ» ដែលក្នុងនោះមានកញ្ចប់«ក» «ខ» និង«គ»មានលក្ខណៈតម្លាភាព និងប្រទាក់ក្រឡាគ្នា ដែលគ្មាននរណាម្នាក់អាចមានឱកាសលួចបន្លំសន្លឹកឆ្នោត ដូចការចោទប្រកាន់របស់ក្រុមប្រឆាំងអគតិនោះទេ។ ជារួម បន្ទាប់ពីការពិនិត្យរាល់ទម្រង់ផ្សេងៗនៅពេលរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផល តួលេខចំនួនសន្លឹកឆ្នោតដែលគណបក្សនីមួយៗទទួលបាននៅគ្រប់ការិយាល័យបោះឆ្នោតនៃខេត្តទាំងពីរខាងលើ គ្មានការប្រែប្រួលឡើយ។ ដើមបណ្តឹងរបស់គណបក្សសង្គ្រោះជាតិនៃខេត្តទាំងពីរទទួលស្គាល់ថា ហត្ថលេខាលើទម្រង់ទាំងអស់ ពិតជាហត្ថលេខារបស់តំណាងគណបក្សខ្លួនមែន។

- នៅខេត្តបាត់ដំបង កញ្ចប់សុវត្ថិភាព «ក»ទាំង៨ ដែលបានពិនិត្យរួច បានបិទយ៉ាងត្រឹមត្រូវ ហើយគ.ជ.ប ក៏បានរកឃើញថា តួលេខចំនួនសន្លឹកឆ្នោតដែលគណបក្សនីមួយៗទទួលបាន ពុំមានការប្រែប្រួលឡើយ នៅការិយាល័យបោះឆ្នោតនីមួយៗ ហើយតួលេខនេះមានសង្គតភាពជាមួយនឹងទម្រង់បែបបទលេខ១១០៤[2] ដែលគណបក្សសង្គ្រោះជាតិមាន។ ទោះជាយ៉ាងណាក្តី ដោយការធ្វេសប្រហែសរបស់មន្ត្រីនៃការិយាល័យ បោះឆ្នោតចំនួន២ មិនបានបំពេញទម្រង់បែបបទលេខ១១០២[3] ប៉ុន្តែមានហត្ថលេខារបស់មន្ត្រីការិយាល័យបោះឆ្នោតទាំងនោះ និងតំណាងគណបក្សនយោបាយ។ រីឯទម្រង់បែបបទលេខ១១០៨ ទម្រង់១១០៤ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត មានទិន្នន័យដូចគ្នានៅការិយាល័យបោះឆ្នោតទាំងពីរ។

- នៅខេត្តកណ្តាល កញ្ចប់សុវត្ថិភាព «ក» ទាំងអស់ ដែលបានពិនិត្យរួច បានបិទយ៉ាងត្រឹមត្រូវ។ នៅក្នុងកញ្ចប់សុវត្ថិភាព «ក» មកពីការិយាល័យមួយ មន្ត្រីការិយាល័យបោះឆ្នោតមានកំហុសដោយច្រឡំដាក់ទម្រង់បែបបទលេខ១១០១ ចំនួនពីរច្បាប់តែម្តង ដែលតាមពិតត្រូវដាក់ទម្រង់បែបបទលេខ១១០១ មួយច្បាប់ និងទម្រង់បែបបទលេខ១១០២មួយច្បាប់ទៀត។ ដូច្នេះ ទម្រង់បែបបទលេខ១១០២ ដែលនៅសល់ចំនួនពីរច្បាប់នោះ ត្រូវបានដាក់ចូលក្នុងកញ្ចប់ «ខ» ហើយផ្ញើទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ទម្រង់បែបបទលេខ១១០៨ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតមានទិន្នន័យដូចគ្នានៅការិយាល័យបោះឆ្នោតនេះ។ ដូចនេះ តួលេខចំនួនសំឡេងឆ្នោតនៅការិយាល័យនេះមិនមានការប្រែប្រួលឡើយ។ ដើមបណ្តឹងពីគណបក្សសង្គ្រោះជាតិទទួលស្គាល់ថា ហត្ថលេខាលើទម្រង់ទាំងនោះពិតជាហត្ថលេខារបស់តំណាងគណបក្សខ្លួនមែន។

[2] ជាទម្រង់ដកស្រង់លទ្ធផលបោះឆ្នោតបឋម ដែលគណបក្សនីមួយៗបានទទួល នៅការិយាល័យបោះឆ្នោតនីមួយៗ បន្ទាប់មក ប្រធានការិយាល័យបោះឆ្នោត ជូនទៅតំណាងគណបក្ស និងអ្នកសង្កេតការណ៍ ដើម្បីជ្រាបជាព័ត៌មាន។

[3] កំណត់ហេតុរាប់សន្លឹកឆ្នោត។

បន្ទាប់ពីបានលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព នៅតាមខេត្តនីមួយៗដែលគណបក្សសង្គ្រោះជាតិបានប្ដឹងរួចមក ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្ដីសម្រេច ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣៖

- តំកល់សេចក្ដីសម្រេចរបស់គ.ជ.ប ទុកជាបានការពេញទាំងមូល
- សេចក្ដីសម្រេចនេះ ជាសេចក្ដីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា ហើយមានអនុភាពទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

ទោះបីជាក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចរួចហើយ រីឯលទ្ធផលបោះឆ្នោតត្រូវបានប្រកាសនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៣កន្លងមក ប៉ុន្តែគណបក្សប្រឆាំងបានបំពានលើច្បាប់ ដោយមិនគោរពតាមការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ច្បាប់បានចែងថា ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាការសម្រេចបិទផ្លូវតវ៉ា ហើយជនណាដែលបំពាននឹងសេចក្ដីសម្រេចនេះ នឹងត្រូវផ្ដន្ទាទោសជាប់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី ១០ម៉ឺនរៀល ដល់ ៦០ម៉ឺនរៀល ឬផ្ដន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរ។

## V. ទស្សនៈរបស់សហគមន៍អន្តរជាតិចំពោះការបោះឆ្នោតនៅកម្ពុជា

បន្ទាប់ពីការបោះឆ្នោត មេដឹកនាំ និងតំណាងគណបក្សនយោបាយពីក្រៅប្រទេសជាច្រើនបានផ្ញើលិខិត ជូនគណបក្សប្រជាជនកម្ពុជាដើម្បីស្វាគមន៍ការបោះឆ្នោតដ៏រលូន និងអបអរសាទរនូវជ័យជំនះចំពោះលទ្ធផលនៃការបោះឆ្នោតសកល។

រដ្ឋាភិបាលជប៉ុនបានស្វាគមន៍ចំពោះការបោះឆ្នោតរដ្ឋសភា នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានរៀបចំឡើងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ថា ជាទូទៅមានលក្ខណៈសន្តិភាព និងរលូន។ រដ្ឋាភិបាលជប៉ុននឹងបន្តតាមដានយ៉ាងយកចិត្តទុកដាក់នូវសភាពការណ៍នៅក្រោយការបោះឆ្នោត ហើយសង្ឃឹមថា ដំណើរការជាបន្តបន្ទាប់ចំពោះបណ្ដឹងតវ៉ា គឺប្រព្រឹត្តទៅក្នុងលក្ខណៈសេរី យុត្តិធម៌ ឆាប់រហ័ស និងប្រកបដោយសន្តិភាព តាមរយៈការចរចា និងកិច្ចសហការរវាងភាគីពាក់ព័ន្ធ អនុលោមទៅតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ហើយធានាឱ្យបាននូវសន្តិសុខនិងរបៀបរៀបរយ។

សហរដ្ឋអាមេរិក អង្គការសហប្រជាជាតិ និងសហភាពអឺរ៉ុប បានចេញសេចក្ដីថ្លែងការណ៍អបអរសាទរចំពោះការបោះឆ្នោតប្រកបដោយសន្តិភាព និងចាត់ទុកថាការបោះឆ្នោតនេះ គឺជាជំហានប្រវត្តិសាស្ត្រ នៅក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យរបស់កម្ពុជា។ សេចក្ដីថ្លែងការណ៍ទាំងនោះក៏បានលើកទឹកចិត្តឱ្យមានការស៊ើបអង្កេតអំពីភាពមិនប្រក្រតីដែលកើតមានឡើង។ ដោយឡែក សហភាពអឺរ៉ុបបានសម្ដែងក្ដីសង្ឃឹមថា «រាល់វិវាទដែលដាក់ជូនគ.ជ.ប និងយន្តការយុត្តាធិការដែលមានស្រាប់នឹងត្រូវបានដោះស្រាយភ្លាមៗ និងប្រកបដោយភាពយុត្តិធម៌»។ លោកសាស្ត្រាចារ្យ Shiro Harada មកពីសកលវិទ្យាល័យតូក្យូ អ្នកសង្កេតការណ៍ជំនាញជប៉ុន បាននិយាយថា «កំហុសដែលកើតចេញពី

ឆ្វេសប្រហែសទាំងនោះ... ប៉ុន្តែខ្ញុំមិនបានឃើញភស្តុតាងច្បាស់លាស់ណាមួយ អំពីការកេងបន្លំលើគណបក្សសង្គ្រោះជាតិទេ។

ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃប្រទេសជាច្រើនដូចជា ចិន ថៃ បង់ក្លាដេស ឡាវ វៀតណាម មីយ៉ាន់ម៉ា ប្រ៊ុយណេ ម៉ាឡេស៊ី ទីម័រខាងកើត គុយ៉ែត បេឡារុស្ស ជាដើម បានផ្ញើលិខិតអបអរសាទរជាបន្តបន្ទាប់ ជូនចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានឈ្នះឆ្នោតបន្តដឹកនាំប្រទេសតទៅទៀត។

## VI. ការបើកកិច្ចប្រជុំលើកដំបូងរបស់រដ្ឋសភា

មាត្រា៨២ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី១បានចែងថា «រដ្ឋសភាបើកសម័យប្រជុំដំបូងហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ»។ ក្នុងមាត្រា៧៦ នៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌទី១ ចែងថា «រដ្ឋសភាមានសមាជិកតំណាងរាស្ត្រយ៉ាងតិច ១២០រូប» មានន័យថា តំណាងរាស្ត្រយ៉ាងតិច ១២០រូប ត្រូវបានជ្រើសរើស ជារៀងរាល់ពេលបោះឆ្នោតសកលដោយឡែក ការបោះឆ្នោតសកលនៅឆ្នាំ២០១៣នេះ សមាជិករដ្ឋសភាមានចំនួន១២៣រូប។ មាត្រាទាំងពីរនេះមិនបានចែងថា សម័យប្រជុំលើកដំបូង ក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រត្រូវមានវត្តមានសមាជិកសភាយ៉ាងតិច ១២០រូបនោះទេ។

បន្ទាប់ពីសម័យប្រជុំដំបូង រដ្ឋសភាអាចបើកសម័យប្រជុំលើកទី១ របស់ខ្លួន ក្រោមអធិបតីភាពប្រធានបណ្តោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោតដែលមានអាយុច្រើនជាងគេ ហើយមានសមាជិកប្រាំរូបជាបេក្ខជនជាប់ឆ្នោតមានអាយុតិចជាងគេ ដែលមានវត្តមានក្នុងកិច្ចប្រជុំជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ។ ក្នុងករណីធម្មតា បើមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម័យប្រជុំលើកទី១នេះ អាចអនុម័តសុពលភាពនៃអាណត្តិរបស់សមាជិករដ្ឋសភានីមួយៗ បោះឆ្នោតជ្រើសរើសប្រធាននិងអនុប្រធានរដ្ឋសភា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការជំនាញរដ្ឋសភាទាំងអស់ ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិក រដ្ឋសភាទាំងមូល ដូចមានចែងក្នុងមាត្រា៨២ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី២និងទី៣ និងប្រការ៥ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលស្ថានភាពនយោបាយតម្រូវ សម័យប្រជុំលើកទី១នេះ អាចអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ។

នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣ មានកិច្ចពិភាក្សាតុមូលបកស្រាយអំពី សម័យប្រជុំលើកដំបូងនៃរដ្ឋសភា ដោយមានការចូលរួមពីសាស្ត្រាចារ្យ និងឥស្សរជនដែលមានចំណេះដឹងនិងបទពិសោធន៍អំពីនីតិរដ្ឋធម្មនុញ្ញ គឺឯកឧត្តម ប៉ែន បញ្ញា ប្រធានគណៈកម្មការនីតិកម្មនិងយុត្តិធម៌នៃរដ្ឋសភា ឯកឧត្តម ឈឹម ផលវរុណ ប្រធានវិទ្យាស្ថានពលរដ្ឋវិទ្យា ឯកឧត្តម ប៊ុន ហ៊ុន ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម ឡាំ ជា សាស្ត្រាចារ្យច្បាប់ ។ កិច្ចពិភាក្សាតុមូលនេះបានបង្ហាញឱ្យឃើញថា សម័យប្រជុំដំបូងក្រោមព្រះរាជាធិបតីភាពរបស់ព្រះមហាក្សត្រ អាច

ប្រព្រឹត្តទៅបាន ដោយមិនចាំបាច់មានកូរ៉ុមនោះទេ ហើយរដ្ឋសភាអាចបើកសម័យប្រជុំលើកទី១ និងសម័យប្រជុំពេញអង្គរបស់ខ្លួនបន្តបន្ទាប់ទៀត ដោយតម្រូវឱ្យមានកូរ៉ុម ដូចមានចែងក្នុងមាត្រា៨៨ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ។

ដូច្នេះ ក្នុងនីតិកាលទី៥នៃរដ្ឋសភានេះ **សមាជិករដ្ឋសភាទាំង៦៨រូបនៃគណបក្សប្រជាជនកម្ពុជា** ចូលរួមសម័យប្រជុំដំបូង**ក្រោមព្រះរាជាធិបតីភាពរបស់**ព្រះមហាក្សត្រ។ បន្ទាប់មក រដ្ឋសភាអាច**បើកសម័យប្រជុំលើកទី១** និងសម័យប្រជុំពេញអង្គបន្តបន្ទាប់ ហើយអាច**ធ្វើការអនុម័តលើបញ្ហាទាំងឡាយណាដែលទាមទារសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល** ដោយគោរពតាមកូរ៉ុមដូចមានកំណត់ក្នុងមាត្រា៨៨ ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ ដែលរួមមាន ការបង្កើតរាជរដ្ឋាភិបាលផងដែរ។

## សន្និដ្ឋាន

ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ នាឆ្នាំ២០១៣ គណបក្សចំនួនពីរបានទទួលអាសនៈក្នុងសភា គឺគណបក្សប្រជាជនកម្ពុជា (៦៨អាសនៈ) និងគណបក្សសង្គ្រោះជាតិ (៥៥អាសនៈ)។ ដោយសារការចោទប្រកាន់ថាមានភាពមិនប្រក្រតី គ.ជ.ប បានដោះស្រាយគ្រប់បណ្ដឹងរបស់គណបក្សសង្គ្រោះជាតិ ហើយស្ថាប័នកំពូល ក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានចេញដីកាបង្គាប់ ឱ្យគ.ជ.ប បើកកញ្ចប់សុវត្ថិភាព ដើម្បីផ្ទៀងផ្ទាត់តួលេខទាំងឡាយ ដែលសង្ស័យថាមានភាពមិនប្រក្រតី។ ក្រុមប្រឹក្សាធម្មនុញ្ញមានចំណាត់ការតាមនីតិវិធី ហើយរកឃើញថា លទ្ធផលនៃការបោះឆ្នោតមិនមានការប្រែប្រួលទេ ហើយកំហុសបច្ចេកទេសក៏មិនបានប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនេះដែរ។ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដែលក្នុងនោះរួមមានស្ថាប័ន ដូចជា ICAPP និង CAPDI បានសាទរ និងវាយតម្លៃខ្ពស់ថា ការបោះឆ្នោតនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ពិតជាបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ទោះបីជាមានកំហុសបច្ចេកទេសបន្តិចបន្តួចដោយអចេតនាក៏ដោយ។ ថ្នាក់ដឹកនាំក្នុងតំបន់ និងពិភពលោក បានផ្ញើសារអបអរសាទរ និងជូនពរជូនគណបក្សប្រជាជនកម្ពុជា និងប្រជាជនកម្ពុជា ដែលបានសម្ដែងឆន្ទៈរបស់ខ្លួនជ្រើសរើសគណបក្សប្រជាជនកម្ពុជា ឱ្យបន្តដឹកនាំរាជរដ្ឋាភិបាលអាណត្តិទី៥ បន្តទៅទៀត។

គណបក្សសង្គ្រោះជាតិគ្មានជម្រើសអ្វីក្រៅតែពីទទួលយកលទ្ធផលនៃការបោះឆ្នោត ដែលប្រសូត្រចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋពិតប្រាកដនោះទេ។ ទោះបីជាលោក សម រង្ស៊ី បានប្រើប្រាស់ល្បិចកលគ្រប់បែបយ៉ាង និងគ្រប់រូបភាពទាំងអស់ ដើម្បីសម្រេចក្ដីស្រមើស្រមៃរបស់ខ្លួនក្លាយជានាយក

រដ្ឋមន្ត្រីក៏ដោយ  ក៏ការពិតនៅតែជាការពិតដដែល  ហើយឱកាសចុងក្រោយតែមួយគត់របស់គាត់បាន រំលងផុតទៅហើយ។   ចំណែកកម្លាំងជំរុញដែលបានកើតឡើងដោយការរួបរួមគ្នានៃគណបក្សប្រឆាំង ទាំងពីរ អាចនឹងមិននៅឋិតថេរយូរអង្វែងទេ។